# ខ្មែរប៉ុស្តិ៍

ផ្សាយខាងកើត

THE KHMER POST

EAST COAST

The Cambodian-American Biweekly News

Email : Khmerpostusa@gmail.com

Call : (267) 253-3947

VOLUME 04 ISSUE 59 May 7th - 20th 2010





# តើស្រុកទេសខ្មែរក្នុងឆ្នាំថ្មី ឆ្នាំខាលនេះ មានទំនាយយ៉ាងណាដែរ?



●●●សង្ក្រាន្តឆ្នាំថ្មីដែលនឹងចូលដល់នៅថ្ងៃទី១៤ មេសា ក្នុងវេលាម៉ោង៧ និង៣៦នាទីព្រឹកក្នុងមហាសង្ក្រាន្ត លោក អ៊ុម ប៊ូរិន្ទ សម្រាប់ឆ្នាំថ្មី ឆ្នាំខាលព.ស ២៥៥៤នេះ មានគណនាអំពីទំនាយជាច្រើន ហើយក្នុងនេះទំនាយកេណ្ឌ ព្រះអាទិត្យបានបង្ហាញថា ឆ្នាំថ្មីនេះព្រះអាទិត្យនឹងធ្វើដំណើរជិះមេឃដែលនឹងអាចមានសឹកសង្គ្រាម ចំណែកក្រុមគ្រួសារណាដែលនឹងសម្រាលកូននៅក្នុងឆ្នាំខាលនេះ កូននោះ គឺល្អបំផុត ហើយដែលទំនាយថា កូនរបស់គ្រួសារនោះគឺជា "អតិជាតិបុត្រ" ។ តាមការគណនារបស់មហា-សង្ក្រាន្តអំពីការកេណ្ឌព្រះភិរុណឆ្នាំនេះ ភ្លៀងក៏មានធ្លាក់ច្រើនសម្រាប់បំរើដល់វិស័យកសិកម្មក្នុងប្រទេសផងដែរ ។

នៅក្នុងមហាសង្ក្រាន្តឆ្នាំខាល ឆ្នាំខ្លារបស់គណៈកម្មាធិការស្រាវជ្រាវហោរាសាស្ត្រ និងប្រពៃណីទំនៀមទម្លាប់ខ្មែរនៃក្រសួងធម្មការ និងកិច្ចការសាសនាដែលរៀបរៀង និងគណនាដោយលោក អ៊ុម ប៊ូរិន្ទ សង្ក្រាន្តឆ្នាំថ្មីនឹងចូលមកដល់ចំថ្ងៃពុធទី១៤មេសា ព.ស ២៥៥៤ វេលាម៉ោង ៧ និង៣៦នាទីព្រឹក ហើយទេព្តាឆ្នាំថ្មីដែលនឹងមកទទួលតំណែងរក្សាសត្វលោកឋានកណ្តាលយើងនេះ គឺជារាជបុត្រីទី៤របស់កបិលមហាព្រហ្មនាមព្រះនាងមណ្ឌាទេវី ។

ដើម្បីឱ្យមានជោគសិរីសួស្តីចូលមានដល់នរូជនគ្រប់រូបនាឆ្នាំថ្មីក្រៅអំពីការរៀបចំបោសសំអាតផ្ទះនិងតុបតែងលំនៅដ្ឋានត្រៀមលក្ខណៈទទួលព្រះនាង មណ្ឌាទេវី ជាទេព្តាឆ្នាំខាល ដែលនឹងហែហមដោយបរិវារជាទេពធីតា និងទេពនិករប្រមាណមួយសែនកោដិ (១០០.០០០លាន) ដោយព្រះនាងទេពធីតាទ្រង់អម្ពរពណ៌អនមានសៀតព្រះកាណ៌ (ត្រចៀក) ដោយផ្កាចំប៉ា ទ្រង់ប្រដាប់ដោយគ្រឿងកែវពិទូរ្យ និងសោយទឹកដោះជាភក្សាហារព្រះហស្តឆ្វេងទ្រង់មូល ព្រះ-ហស្តស្តាំទ្រង់ឈើច្រត់ និងគង់ឈរលើខ្នងគទ្រភ: (សត្វលា) ជាជំនិះនោះ ជនានុជនទាំងឡាយគួរគប្បីមានរៀបរណ្តាប់ទទួលទេព្តាឱ្យបានត្រឹមត្រូវទៅតាមជំនាឆ្នាំ ។

ចំពោះរណ្តាប់ និងរបៀបរៀបចំទទួលទេព្តាឆ្នាំថ្មី គឺត្រូវរៀបចំធ្វើនៅចំមុខផ្ទះដោយក្រាលសំពត់ពណ៌ស ឬស្រគាំបន្ទិច មានរៀបបាយសី៩ថ្នាក់១គូ ៧ថ្នាក់១គូ ៥ថ្នាក់១គូ ៣ថ្នាក់១គូ ទឹកអប់១គូ ទៀន៥ ធូប៥ លាជ៥ ដាក់លើជើងពាន១គូ ចេកនួនឬចេកណាំវ៉ាដាក់២ជើងពាន ផ្លែឈើ១១មុខ ដាក់លើជើងពាន១គូ ដូងខ្ចីឡៅ១គូ និងទឹកស្អាត២កែវ ។ បើយកល្អឆ្នាំនេះ ដោយទេព្តាសោយទឹកដោះជនានុជន ក៏គួររៀបដាក់ទឹកដោះស្រស់បន្ថែមផងនោះកាន់តែប្រសើរ ។ (តទៅទំព័រទី ១៩)

# នាយកក្រសួងអប់រំនៅហ្វីឡាដែលហ្វៀបានសន្យា


លោកស្រី អាគីម៉ាន់

**ខ្មែរប៉ុស្តិ៍ :** គឺនៅក្រោមផ្ទាំងគំនូរដ៏មានន័យធំមួយនាវត្តព្រះពុទ្ធរង្សីលោកស្រីនាយកក្រសួងអប់រំ "អាគីម៉ាន" បានសន្យាដល់សហគមន៍ខ្មែរ នៅហ្វីឡាដែលហ្វៀ ដែលមានវត្តមានប្រមាណជា ១០០ នាក់ថា "ខ្ញុំស្តាប់សំណើររបស់អ្នក ខ្ញុំគាំទ្រដល់ការសិក្សារបស់កូនលោកអ្នកឱ្យដូចជាការសិក្សារបស់កូនខ្ញុំដែរ ខ្ញុំនឹងនៅជាមួយសហគមន៍លោកញអ្នក ដើម្បីដោះ-ស្រាយគ្រប់បញ្ហាដែលកើតមាន"...។



សហគមន៍ខ្មែរនាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០ តំណាងដោយព្រះគ្រូចៅអធិការ រដ្ឋ មុនី ដោយសហគមន៍ខ្មែរ និងបញ្ញាវន្តខ្មែរមួយចំនួន បានទាមទារឱ្យទទួលស្គាល់ថា តួរលេខចំរុះសាសន៍ ដែលសំដៅរកសិស្សដែលបានបោះបង់សាលានោះ ជាមធ្យមភាពសម្រាប់ខ្មែរមិនយុត្តិធមិទេ គឺមានចំនួនច្រើនជាងគេដាច់ខាត ដែលជាហេតុធ្វើឱ្យក្រសួងអប់រំជួយកូនខ្មែរមិនបានជិតដល់ ។

(តទៅទំព័រទី ០៩)






Totally Traditional!
Totally Cambodielicious!
ទាបំពងទឹកត្រីអំពិលទុំ
KAVEI CAMBODIAN RESTAURANT
Authentic Khmer • Thai • Lao • Vietnamese Phở
320 W OREGON AVENUE
(OREGON MARKET, SOUTH PHILLY)
215.952.6688
OPEN 7 DAYS A WEEK
9am-10pm

# កៅអីប្រធានសមាគមព្រឹទ្ធាចារ្យមានអ្នកថ្មីអង្គុយហើយ


លោក អ៊ូ កៅ


អ៊ុក ហាក់


ជិន វុត្ថា និង វ៉ា សាមុន

ដោយ : អ៊ុម លឿម

•••សមាគមព្រឹទ្ធាចារ្យខ្មែរ-អាមេរិកាំងប្រចាំទីក្រុងហ្វីឡាដែលហ្វៀ នាថ្ងៃអាទិត្យ ទី២៥ ខែមេសា កន្លងមកនេះ បានធ្វើការបោះឆ្នោតជ្រើសរើសនូវប្រធានថ្មីរបស់ខ្លួន បន្ទាប់សមាគមមួយនេះ បានផ្ទុះនូវរឿងចម្រូងសម្រាស់ពីបញ្ហាផ្ទៃក្នុង រហូតមានការប្តឹងប្តល់គ្នាឡើងតុលាការជាច្រើនលើកច្រើនគ្រារួចមក ។

ទោះបីជាប្រធានថ្មីមានវ័យចំណាស់ គឺលោក អ៊ូ កៅ អតីតប្រធានសមាគមខ្មែរ នាទសវត្សរ៍ឆ្នាំ ១៩៨៩-១៩៩៧ បានជាប់ឆ្នោតជាប្រធានថ្មីក្តី ក៏មកដល់ពេលនេះ គេនៅមិនទាន់បានដឹងដែរថា តើវិវាទផ្ទៃកផ្លូវច្បាប់ដែលបានអូសបន្លាយជាងមួយឆ្នាំមកហើយនោះ អាចនឹងរលត់ ឬនៅបន្តការប្តឹងប្តល់គ្នាទៀត ? ពីព្រោះបើសំអាងលើការថ្លែងប្រាប់ពីលោក ជិន វុត្ថា អតីតប្រធានស្តីទីរបស់អង្គការមួយនេះ ហាក់បង្ហាញអំពីភាពមិនច្បាស់លាស់របស់ខ្លួនថាតើសមាគមព្រឹទ្ធាចារ្យខ្មែរ-អាមេរិកាំង ឬ CASA នឹងបញ្ចប់ទំនាស់ផ្ទៃក្នុងត្រឹមហ្នឹង ឬយ៉ាងណានោះ? ។


លោក សារិន ជូ


សមាជិកចូលរួមបោះឆ្នោត

លោក ជិន វុត្ថា បានថ្លែងនៅក្នុងថ្ងៃបោះឆ្នោតថា "យើងនៅពុំទាន់ដឹងថា តើខាងលោក វណ្ណា ឈប់ប្តឹង ឬគេមិនសប្បាយចិត្ត នៅបន្តប្តឹងមកលើយើងទៀត នោះជារឿងរបស់គេ..." ។

**CASA លើកថ្ងៃបោះឆ្នោត**

យោងតាមការប្រកាសជូនដំណឹងរបស់ CASA បានឱ្យដឹងថា គេដឹងធ្វើការបោះឆ្នោតនៅថ្ងៃសៅរ៍ ទី២៤ មេសា ។ ប៉ុន្តែកាលបរិច្ឆេទខាងលើនេះ ត្រូវបានលុបចោល ដោយលើកទៅថ្ងៃអាទិត្យ ទី២៥ វិញ ។ ការលើកថ្ងៃបោះឆ្នោតនេះ ត្រូវបានទទួលនូវការរិះគន់មួយចំនួនពីសំណាក់អ្នកតាមដានព្រឹត្តិការណ៍សង្គមក្នុងហ្វីឡាដែលហ្វៀ ។ "ខ្មែរប៉ុស្តិ៍" បានទៅដល់ទីស្នាក់ការ CASA ថ្ងៃទី២៤ តាមកាលកំណត់ ប៉ុន្តែក្នុងស្នាក់ការ CASA មានមនុស្សតែពីរនាក់ប៉ុណ្ណោះ កំពុងធ្វើការបោសសំអាត ។

ចំពោះបញ្ហាខាងលើគណកម្មការ CASA បានធ្វើការបកស្រាយថា "មូលហេតុដែលនាំឱ្យមានការលើកថ្ងៃបោះឆ្នោតនោះ ពីព្រោះថ្ងៃទី២៤ ជាថ្ងៃដែលគេប្រារព្ធធ្វើបុណ្យចូលឆ្នាំខ្មែរ ហើយគណកម្មការម្នាក់ៗ សុទ្ធសឹងតែជាប់ភារកិច្ចរៀងៗខ្លួន ដូច្នេះ ទើបសម្រេចដូរទៅថ្ងៃអាទិត្យ ទី២៥ វិញ " ។

**ការបោះឆ្នោតមានលក្ខណៈចម្លែក**

បេក្ខជនឈរឈ្មោះក្នុងការបោះឆ្នោតដើម្បីនឹងក្លាយជាប្រធានថ្មីមានចំនួនតែពីររូបប៉ុណ្ណោះ គឺលោក អ៊ុក ហាក់ ជាអតីតអគ្គហិរញ្ញិករបស់សមាគម និងលោក អ៊ូ កៅ ។ ជាលទ្ធផលលោក អ៊ូ កៅ ជាអ្នកទទួលជ័យជំនះលើលោក អ៊ុក ហាក់ ដោយ ២០ ទល់នឹង ១២សម្លេង ។ ចំពោះប្រការចម្លែកមួយដែលធ្វើឱ្យអ្នកចូលរួមបោះឆ្នោតមួយចំនួនមានការងឿងឆ្ងល់ គឺនៅត្រង់លោក អ៊ូ កៅ មានភារៈជាគណកម្មការបោះឆ្នោត ហើយអ្នករៀបចំការបោះឆ្នោត ក៏ត្រូវបានជាប់ឆ្នោតក្លាយជាប្រធានថ្មីភ្លាមដែរ ។

**ប្រធានថ្មីចាប់ផ្តើមធ្វើការនៅដើមខែ ៦**

តាមការឱ្យដឹងពីគណកម្មការរបស់ CASA បានឱ្យដឹងថា ប្រធានថ្មីនឹងចាប់ផ្តើមធ្វើការនៅក្នុងការិយាល័យដ៏ទ្រុឌទ្រោមមួយនេះ នៅថ្ងៃទី០១ ខែមិថុនា ខាងមុខនេះហើយ ។ ក៏ប៉ុន្តែខាងគណកម្មការហាក់នៅពុំទាន់រៀបចំនូវរចនាសម្ព័ន្ធថ្មីឱ្យបានរលូននៅឡើយទេ បន្ទាប់ពីប្រកាសរំលាយនូវរចនាសម្ព័ន្ធចាស់ចោល នៅថ្ងៃទី២៥ ដែលជាថ្ងៃបោះឆ្នោតនោះ ប៉ុន្តែលោក អ៊ូ កៅ ដែលជាប្រធានថ្មី បានប្រកាសរក្សាលោក អ៊ុក ហាក់ ជាអគ្គហិរញ្ញិកដដែល ។

**តើ CASA នៅជាប់បំណុលរដ្ឋអ្វីខ្លះ ?**

តាមការបំភ្លឺជាចំហរមួយរបស់លោក អ៊ុក ហាក់ នាថ្ងៃបោះឆ្នោត បានឱ្យដឹងថា បច្ចុប្បន្ន CASA មានទឹកប្រាក់ជាង ៣ម៉ឺនដុល្លារ នៅក្នុងហិបគណនី ។ ប៉ុន្តែគណកម្មការរបស់ CASA បានសារភាពថា គេនៅពុំទាន់បានដឹងនូវតួរលេខពិតប្រាកដនៃការជំពាក់លើខ្ទង់ចំណាយផ្សេងៗ នាពេលកន្លងមកប៉ុន្មានឡើយ ដោយខ្ទង់ចំណាយនោះរាប់បញ្ចូលទាំងការជំពាក់លើថ្លៃបង់ទឹក, ភ្លើង, ម៉ាស៊ីនកំដៅ (Heat) និងសំខាន់ជាងគេនោះ គឺជំពាក់លើការបង់ Wax Tax ។ នេះជាការបញ្ជាក់របស់លោក ជិន វុត្ថា ។

**ស្តាប់ការពន្យល់របស់ប្រធានចាស់**

"ដោយឃើញភាពខុសពីប្រក្រតីនៅក្នុងសមាគម ទើបគណកម្មការយើងសំណូមពរឱ្យលោក ងួន វណ្ណា លាលែងដោយសន្តិវិធី ហើយគណកម្មការយើងនឹងផ្តល់ប្រាក់បៀវត្តន៍សមស្រប ប៉ុន្តែគាត់ពុំព្រម ទើបយើងធ្វើលិខិតជាលាយលក្ខណ៍អក្សរបណ្តេញគាត់តែម្តង... ។ នេះជាការពន្យល់បកស្រាយរបស់លោក សារិន ជូ ដែលបានលាលែងពីមុខតំណែង ដោយហេតុផលបញ្ហាសុខភាព ។

តាមការពន្យល់របស់លោក សារិន ជូ បានឱ្យដឹងថា បន្ទាប់ពីលោក វណ្ណា ត្រូវបានបណ្តេញចេញពី CASA ហើយនោះ ខាងលោក វណ្ណា បានបង្កើតគណកម្មការថ្មីមួយក្រុម ដើម្បីតតាំងជាមួយ CASA បច្ចុប្បន្ន ប៉ុន្តែជាអកុសលក្រុមនេះត្រូវបានរំលាយទៅវិញ ហើយសមាគមនៃក្រុមនោះ បានដើរចេញពីលោក វណ្ណា ដោយមិនតតាំងជាមួយ CASA ឡើយ ។ នៅមិនស្ងៀមឡើយ លោក វណ្ណា ក៏បានបង្កើតក្រុមទីពីរផ្សេងមួយទៀត ហើយក្រុមទីពីរនេះហាក់មានជំហររឹងមាំក្នុងការគាំទ្រលោក វណ្ណា ។

**អណ្តាតភ្លើងនៃ CASA ហាក់ពុំទាន់រលត់**

គេនៅពុំទាន់ជាក់ច្បាស់ថា តើអធិការណ៍រវាងមនុស្សទាំងពីរក្រុមនេះ អាចបញ្ចប់ត្រឹមហ្នឹង ឬក៏អាចនឹងមានការប្តឹងប្តល់គ្នាយ៉ាងណាទៀតឡើយ ។ ខាង CASA បច្ចុប្បន្នហាក់បានបង្ហាញពីចេតនាបញ្ចប់អធិការណ៍ដ៏រ៉ាំរ៉ៃជាមួយលោក វណ្ណា ដែលត្រូវបានដកពីតំណែង ប៉ុន្តែខាងលោក វណ្ណា ហាក់មិនបានបញ្ចេញចេតនារបស់ខ្លួន ថាតើនៅបន្តក្តីក្តាំងផ្នែកផ្លូវច្បាប់ ឬបញ្ចប់វិវាទត្រឹមហ្នឹង ? ។ ខ្មែរប៉ុស្តិ៍ ធ្លាប់បានទាក់ទងទៅលោក ងួន វណ្ណា ដើម្បីសុំការបំភ្លឺនានា ជុំវិញបញ្ហាចម្រូងចម្រាស់ខាងលើ ប៉ុន្តែទូរស័ព្ទរបស់លោកគ្មានអ្នកទទួលឡើយ ។

ព័ត៌មានថ្មីៗជុំវិញ CASA ឬក៏ប្រតិកម្មនានារបស់ក្រុមវិវាទទាំងសងខាង "ខ្មែរប៉ុស្តិ៍" នឹងជម្រាបជូននៅពេលក្រោយ ៕



# ទិវាស្វែងយល់អំពី សុខភាពសម្រាប់ស្ត្រីអាស៊ី-អាមេរិកាំង ឆ្នាំទីប្រាំមួយ



## ថ្ងៃសៅរ៍ ទី៥ ខែមិថុនា ឆ្នាំ២០១០

### ម៉ោង ១០ ព្រឹក ដល់ ២:៣០ រសៀល

**នៅសណ្ឋាគារ Sheraton Philadelphia City Center Hotel**

**ផ្លូវ 17th & Race Streets, Philadelphia**

មិនបាច់បង់ថ្លៃ ... សិក្ខាសាលាអំពីសុខភាពស្ត្រីមានជាភាសាអាស៊ីផ្សេងៗ

មិនបាច់បង់ថ្លៃ ... សិក្ខាសាលាថ្មី សម្រាប់អ្នកនៅរស់ពីរោគមហារីក និងអ្នកមើលថែរបស់ពួកគេ

គេនឹងផ្តល់អាហារពេលថ្ងៃ

មានព័ត៌មានផ្សេងៗអំពីសហគមន៍អាស៊ី

មានគ្រឿងកំសាន្តពីសហគមន៍អាស៊ី

មានឱកាសចុះឈ្មោះចតមើលដោះ ដោយឥតបង់ថ្លៃ

American Cancer Society

THE OFFICIAL SPONSOR OF BIRTHDAYS.

Susan G. Komen for the Cure PHILADELPHIA

cancer.org | 1.800.227.2345
komenphiladelphia.org | 215.238.8900

---

**ក្រដាស់បំពេញដើម្បីចុះឈ្មោះ** (សូមផ្ញើក្រដាស់បំពេញដើម្បីចុះឈ្មោះនេះមកវិញត្រឹម ថ្ងៃសុក្រ ទី១៩ ខែ ឧសភា ឆ្នាំ២០១០)

ឈ្មោះ: ______________________ លេខទូរស័ព្ទ: ______________

អាស័យដ្ឋាន: ______________________ ទីក្រុង __________ រដ្ឋ: ________ ស៊ីពខូដ: __________

* សូមរើសយកភាសារបស់អ្នក និង **សិក្ខាសាលាតែមួយគត់។**

| | | |
|---|---|---|
| ☐ ខ្មែរ | ☐ ចិនម៉ង់ដារិន | ☐ ចិនកាន់តូនីស |
| ☐ គូចារ៉ាទី/ហិុនឌី | ☐ ឥណ្ឌូណេស៊ី | ☐ កូរ៉េ |
| ☐ មេឡាយ៉ាឡាំ | ☐ វៀតណាម | ☐ អង់គ្លេស |

ឬ

☐ *ថ្មី!!* សិក្ខាសាលានឹងផ្តល់ឲ្យតែ អ្នកនៅរស់ពីរោគមហារីក និងអ្នកមើលថែរបស់ពួកគេតែប៉ុណ្ណោះ។ (គេនឹងផ្តល់អ្នកបកប្រែភាសាឲ្យ។

សូមជំរាបយើងខ្ញុំនូវភាសារបស់អ្នក: ______________________)

**សូមផ្ញើទៅ:** Wan Ling Hung, American Cancer Society,
1626 Locust Street, Philadelphia, PA 19103

**ឬ ទូរសារ (fax) ទៅ:** 215.985.5406

**ទូរស័ព្ទ:** Hasven Lim, SEAMAAC, 215.467.0690 x28 (ខ្មែរ)

(Cambodian)

អត្ថបទមនោសញ្ចេតនា

# ក្ដីស្នេហ៍គ្មានទីបញ្ចប់...!



**ដោយ : គឹម ភៀន** ***(តពីលេខមុន)***

•••សង្គ្រាមហែកហួរខ្មែរ និងខ្មែរបានរីករាលដាល់ដល់កំពូលហើយ ។ ខាងខ្មែរក្រហមបានយួនយៀកកុង និងយួនខាងជើងកុម្មុយនិស្ដឈរពីក្រោយ ដោយជំនួយចិន និងសូវៀត ចាក់បង្ហូរមកឱ្យ ឯខាងលោកប្រមុខ លន់ នល់ បានសហរដ្ឋអាមេរិក និងលោកខាងលិចបន្តក់ជំនួយដោយដំណាត់ៗមកឱ្យទប់ទល់នឹងសង្គ្រាមមួយដែលគ្មានសង្ឃឹមថា អាចទប់ទល់បាននឹងការឈ្លានពានរបស់សត្រូវបរទេសឡើយ ។ នយោបាយ និងកលល្បិចរបស់សាធារណរដ្ឋខ្មែរ នៅក្មេងខ្ចីណាស់ចំពោះកលល្បិចកញ្ច្រោងកុម្មុយនិស្ដយួនខាងជើង ។ ពឹងទៅលើសង្គ្រាមកម្លាំងទ័ពសាធារណរដ្ឋខ្មែរ មានភាពដូចឈរនៅមាត់ជ្រោះ ហើយទប់នឹងកម្លាំងច្រានសំរុកពីសត្រូវ ដែលមានកម្លាំងខ្លាំងក្លាជាង ហេតុនេះអ្នកស្រឡាញ់លទ្ធិប្រជាធិបតេយ្យដឹងខ្លួនថា អនាគតនឹងទៅជាយ៉ាងណា ។ បន្ថែមពីលើនេះទៀត សម្បូរដោយជនឱកាសនិយម ចាក់ខ្សែ ពុលរលួយ ធ្វើឱ្យភាពបរាជ័យនៃអ្នកសាធារណរដ្ឋនិយមកាន់តែលំបាកនឹងទប់ទល់ ។ ខាងផ្នែកទឹកដីកាន់កាប់ដោយកងទ័ពសាធារណរដ្ឋកាន់តែរបេះបាត់ទៅលើដៃខ្មែរក្រហម យួនកុម្មុយនិស្ដកាន់តែច្រើនឡើងៗ ធ្វើឱ្យសាធារណរដ្ឋខ្មែរកាន់តែរួញតូចៗទៅ ខេត្តខ័ណ្ឌខ្លះនៅសល់តែទីរួមខេត្តហ៊ុំព័ទ្ធដោយសត្រូវនៅជុំវិញខ្លួន ។ ប្រជាពលរដ្ឋនៅតំបន់ទាំងនោះក៏ដូចជាកងទ័ពដែរត្រូវរស់ដោយជំនួយពីបរទេស ចំណី អាហារ ថ្នាំពេទ្យត្រូវបានយន្តហោះទម្លាក់មកឱ្យពីលើអាកាស ។

ផ្លូវទៅកាន់ស្រុកតាំងគោកត្រូវកាត់ផ្ដាច់ជាញឹកញាប់ ។ តែការរក្សាភាពចងភ្ជាប់នៃភ្នំពេញ និងតាំងគោកនៅតែមានភាពរលូន ដោយសារជើងអាកាស ។ លិខិតឆ្លងឆ្លើយរវាងអ្នកគ្រូបុប្ផា និងអនុសេនីយ៍ឯក គឹម វិរៈ នៅតែបន្តទៅមុខបានដោយសារឆ័ត្រយោងពីលើអាកាសម្ដងម្កាលដែរ ។

ក្រោយពេលសរសេរលិខិតផ្ញើអ្នកគ្រូបុប្ផាយ៉ាងវែងនោះមក វិរៈ ក៏រវល់តែនឹងភារៈកិច្ចទប់ទល់ខ្មាំងសត្រូវដែលចេះតែចូលមកវាយលុករុករានរំខាន ក៏មិនសូវមានពេលទឹកនឹងរង់ចាំលិខិតឆ្លើយតបពីសង្សាឡើយ ។

ព្រឹកមួយកំពុងអានរបាយការណ៍នៅក្នុងការិយាល័យ លោកអនុ-សេនីយ៍ឯក វិរៈ បានទទួលលិខិតឆ្លើយតបពីគូស្នេហ៍មួយ ដោយសប្បាយរីករាយបំផុត ។

***អង្គតាសោម នៅរដូវផ្កាក្រោកចាប់ផ្ដើមរីករាយ !***

បងជាយុទ្ធជនគួរឱ្យស្រឡាញ់ អូនបានអានសំបុត្រដ៏វែងរបស់បងរួចអស់ហើយ អូនមានការរំភើបរីករាយយ៉ាងក្រៃលែង ។ នឹកស្មានថាមានយុទ្ធជនលីដែកលក់ជីវិតជូនមាតុភូមិដូចបង អូនត្រូវតែមានជីវិត និងអារម្មណ៍សោះកក្រោះដូចខែប្រាំងរីងស្ងួតនៃវាលស្រែអង្គតាសោម ដែលមានតែកញ្ច្រាំងឆេះខ្លោចដោយអ្នកស្រុកប្រុងប្រៀបវាលស្រែរបស់ខ្លួនទុកសម្រាប់រដូវវស្សាបន្ទាប់ទៀត... បងពិតជាសម្បូរការស្រមៃដែលធ្វើឱ្យអ្នកគ្រូម្នាក់សុំទទួលស្គាល់ថា ខ្លួនបានចាញ់ការនិពន្ធរបស់បងហើយ ហើយចង់អានទូវសំណេរលិខិតផ្សេងៗរបស់បងតទៅទៀត ។ អូនពិតជាពុំត្រូវមានជីវិតសោះកក្រោះនៃនារីម្នាក់រង់ចាំប្រុសសង្សាខ្លួន នៅឯសមរភូមិឡើយ ។ អូនពិតជាសប្បាយចិត្តរង់ចាំបងក្នុងកិត្តិយស និងក្ដីអំនួត ។ មិនស្មានថា ថ្ងៃរៀបអាពាហ៍ពិពាហ៍របស់យើងបានខិតចូលមកជិតហួសពីការស្មានរបស់អូនយ៉ាងនេះសោះ អរគុណបងណាស់ ដែលបានគិតគូជានិច្ចដល់អូន ។ ពិតណាស់ហើយនារីម្នាក់រង់ចាំថ្ងៃរៀបការពីបុរសម្នាក់ដែលនៅដាច់ស្រយាលពីខ្លួន មានអារម្មណ៍ភ័យខ្លាច សោកសង្រេងយ៉ាងណា គឺអូនមានអារម្មណ៍យ៉ាងនោះឯង... មានយប់ខ្លះគេងយល់សប្តិឃើញបង ហើយបាត់បងនៅក្នុងភាពងងឹតនៃផ្សែងរំសេវ ។ អូនខ្សឹបខ្សួលអូលអាក់ទាល់តែភ្ញាក់ពីដំណេក ដឹងខ្លួនថាយល់សប្តិទឹកភ្នែកអូនបានជោជនលើថ្ពាល់ ។

ផ្ទុយទៅវិញការប្រាថ្នារបស់បងថា ថ្ងៃរៀបការរបស់យើង អូន និងបងបានជិះលើខ្នងដីរជាមួយគ្នា ហែរព័ទ្ធវិមានឯករាជ្យបីជុំ រួចហើយទើបវិលចូលរោងការធ្វើពិធីផ្សេងៗតាមប្រពៃណីទៀតនោះ ពិតជាធ្វើឱ្យអូនរំភើបក្រៃលែង... ។

តែមានរឿងម្យ៉ាងដែលអូនមិនអាចធ្វើតាមបណ្ដាំរបស់បងបានភ្លាមៗនោះ គឺការសុំផ្លាស់ទៅភ្នំពេញ ។ នៅតែ២ខែទៀតសិស្សនឹងត្រូវប្រឡង អូនត្រូវរង់ចាំបង្រៀនឱ្យចប់កម្មវិធីស្រួលបួលសិន កុំឱ្យសិស្សទាំងនេះជួបប្រទះឧបសគ្គដោយពុំចប់កម្មវិធី ឬដោយត្រូវមានគ្រូថ្មីមកជំនួសអូន ធ្វើឱ្យមានការរអាក់រអួលក្នុងការបញ្ចប់កម្មវិធីរបស់ប្អូនៗទាំងនេះ ។ ក្រោយពីបញ្ចប់កម្មវិធីភ្លាម អូននឹងសូមផ្លាស់ទៅភ្លាមតាមពាក្យណែនាំទាំងអស់របស់បង ។ ម្យ៉ាងទៀត លោក ថាច់ ជា ធ្លាប់ជាគ្រូរបស់អូន កាលអូននៅរៀនសាលាភ្នំដូនពេញដែរ ពិតជាគាត់សប្បាយចិត្តពេលបានជួបសិស្សរបស់គាត់ ដែលបានរើសអាជីពជាគ្រូបង្រៀនដូចគាត់ដែរ ។

តាមទីធ្លាសាលាផ្កាក្រោកចាប់ផ្ដើមរីកក្រហមឆ្អៅ ធ្វើឱ្យអូននឹកស្រមៃកាលយើងនៅជាសិស្ស ។ យើងខ្វាយខ្វល់ណាស់ពេលឃើញផ្កាក្រោករីកតាមវិថីទ័ព្វជុំវិញវិមានឯករាជ្យ ព្រោះមេរៀនមិនចេះចប់លំហាត់ទាំងឡាយពុំទាន់បានចេះស្ទាត់ តែថ្ងៃប្រឡងចូលមកបន្តិចម្ដងៗជាមួយនឹងរដូវផ្កាក្រោករីកពេញរដ្ឋធានីភ្នំពេញ ។ ហេតុនេះហើយអូនមិនចង់ឱ្យសិស្សមានបញ្ហាចំពោះមុខវិជ្ជារបស់អូនបូកបន្ថែមពីលើបញ្ហាដែលគ្នាកំពុងមានសព្វថ្ងៃ ។ អូននឹងដកខ្លួនពីអង្គតាសោមភ្លាម ពេលអូនបញ្ចប់កម្មវិធីសិក្សារបស់អូនចំពោះសិស្សទាំងនោះ ។

សូមបងយល់ និងអធ្យាស្រ័យចំពោះការដែលអូនយឺតយ៉ាវនេះ ។ អូននឹក និងស្រឡាញ់បងជានិច្ច ។

*ពីអូន : កល្យាណបុប្ផា*

**(រង់ចាំអានបន្តនៅលេខក្រោយទៀត)**

*ឆ្លើយតបសំនួរមិត្តអ្នកអាន*

# Three Cups of Tea
# ទឹកតែ៣ពែង **(តពីលេខមុន)**



**ដោយ : គឹមភៀន**

*សរសេរតាមលំនាំរឿងពិត*

•••ទោះបីលោក គ្រែក ធ្លាប់ហិតក្លិនតែប៉ាយូឆានេះច្រើនដង ឃើញថា គេមិនអាចលេបចូល ហើយប្រើពាក្យយ៉ាងទន់ភ្លន់ដើម្បីសុំឱ្យរួចខ្លួនអំពីការដែលត្រូវតែផឹកតែបែបនេះជាការគួរសមនោះ ព្រោះតាមការស្មានរបស់គេតែប៉ាយូឆានេះ មានក្លិនអាក្រក់ជាងបឿស្អុយរបស់បារាំងទៅទៀត ប៉ុន្ដែប៉ាយូឆា ជាជំពូកទឹកតែពិសេសរបស់ជនជាតិបាល់ទី (Balti) នៃកុល-សម្ព័ន្ធដែលរស់នៅលើជម្រាលភ្នំខ្ពស់ភាគខាងជើងនៃប្រទេសប៉ាគីស្ថាន ។ កុលសម្ព័ន្ធនេះហើយ ដែលមូហ្សាផឿ ជននាំផ្លូវរបស់ គ្រែក បានរស់នៅ ។

ម្ដងនេះសម្លឹងមូហ្សាផឿបង្កាត់ភ្លើងឆុងតែប៉ាយូឆា គ្រែក មិនប្រកែក តែខំសម្លឹងការឆុងតែនេះយ៉ាងយកចិត្តទុកដាក់ ។ គេបង្កាត់ភ្លើងដាំទឹកក្នុងឆ្នាំងមួយគេចាក់តែប៉ាយូឆាចូលក្នុងទឹកនោះ ព្រមទាំងបឿជាមួយគ្នា ហើយយកម្រាមដៃកូរឱ្យរលាជាតិតែប៉ាយូឆា និងបឿឱ្យរលាយចូលជាតិគ្នា ។ ទឹកតែនេះមានពណ៌ដូចកាហ្វេទឹកដោះគោយ៉ាងនោះដែរ ។ ពេលទឹកតែនេះបានក្ដៅរួចពុះស្រេចបាច់ហើយ មូហ្សាផឿបានដួសមួយកែវធំ ដែលមានដៃកាន់ហុចឱ្យគ្រែក ។ ម្ដងនេះគេមិនប្រកែកទេ ម្យ៉ាងរាយកាយរបស់គេហាក់ដូចត្រូវការភេសជ្ជៈក្ដៅនេះជួយកំដៅឱ្យបានកក់ក្ដៅឡើងវិញ ។ គ្រែកទទួលយក ហើយផឹកដោយភាពស្រេកឃ្លាន ។ គេទទួលមួយកែវ ហើយមួយកែវទៀត រហូតដល់អស់កែវទីបី ។ គេមានកម្លាំងគ្រាន់បើឡើងវិញហើយ ក៏នាំគ្នាបន្តដំណើរទៅមុខទៀតយ៉ាងប្រុងប្រយ័ត្ន ។ ម្ដងនេះអ្នកនាំផ្លូវមូហ្សាផឿមិនបណ្ដោយឱ្យឃ្លាតឆ្ងាយពីគ្នាទៀតទេ ។ ជួនកាលគេឱ្យគ្រែកដើរពីមុខគេ ជួនកាលគេឱ្យគ្រែកដើរពីក្រោយសឹងតែជាន់កែងគេ ។ គេនាំគ្នាដើរតម្រង់ទៅរកភូមិអាស់ស្កុលនៃជនជាតិបាទីរបស់មូហ្សាផឿរស់នៅផង និងខំរៀនភាសាបាល់ទីបណ្ដើរផង ។

គេខំធ្វើដំណើរយ៉ាងឿនហាត់នេះ អស់រយៈពេលបីថ្ងៃ ។ ថ្ងៃទីបីនេះ គ្រែកបានបោះជំហានដំបូងចេញពីដីដែលក្រាលដោយទឹកកក ហើយបានដើរលើដីស្ងួតរាបធម្មតាដែលមានស្មៅដុះ ។ អស់រយៈពេលបីខែហើយ ដែលគ្រែករស់នៅតែលើផ្ទាំងទឹកកក ។ គេសប្បាយចិត្តពន់ពេក ដោយបានចុះមកពីលើកំពូលភ្នំ ហើយបានជាន់លើដីស្ងួតធម្មតានេះ ។

គេក៏បានដើរសរសៀតាមមាត់ទន្លេមួយដែលមានឈ្មោះថា Braldu តម្រង់ទៅកាន់ភូមិអាស់ស្កុល ។ ដោយដឹងថាគ្រែកលែងច្រឡំផ្លូវទៀតហើយ មូហ្សាផឿក៏បណ្ដោយឱ្យគ្រែកដើរយ៉ាងយឺតៗ និងនឿយហត់ជើងទាំងពីរចុករោយបោះជំហានម្ដងមួយជំហានៗ ឯមូហ្សាផឿខំស្រូតដំណើរទៅមុខ ដើម្បីបានបោះតង់ (ជំរំ) ឱ្យគ្រែកដើរតាមឆ្នេរទន្លេនេះ ពេលទៅជួបគ្នាគ្រែកនឹងមានកន្លែងសម្រាក ។ ម្យ៉ាងទៀតកន្លែងបោះជំរំនោះនឹងមានផ្សែងចេញពីភ្នក់ភ្លើងដែលមូហ្សាផឿបង្កាត់ទុកប្រចាំជំរំជាសញ្ញាឱ្យគ្រែកអាចតម្រង់ទិសបានដែរ ។ ជឿជាក់យ៉ាងនេះ គេក៏ស្រូតដណើរទៅមុខគ្រែក រៀបចំជំរំព្រោះពេលអស្ដង្គត់ជិតចូលមកដល់ទៀតហើយ ។

គ្រែកដើរតាមឆ្នេរទន្លេ Braldu បណ្ដើរ សម្លឹងទៅមុខគយគន់ទេសភាពបណ្ដើរ គេក៏បានឃើញដើមស្រល់៥ដើមដុះឡើងខ្ពស់ត្រដែតនៅឯជើងមេឃពីខាងមុខគេ ។ គិតទៅថ្ងៃនេះជាថ្ងៃទី៧ដែលគេបានចុះពីកំពូលភ្នំ ក២ (K2) ។ កំពូលចុងស្រល់ទាំងប្រាំនោះជាសញ្ញាបង្ហាញថា ទីកន្លែងមានមនុស្សរស់នៅព្រោះដើមស្រល់ទាំងនោះដុះឡើងដោយសារអ្នកភូមិគេដាំវា មិនមែនជាដើមស្រល់ដុះក្នុងព្រៃដោយសារធម្មជាតិនោះទេ ។ គិតដូច្នេះហើយ គ្រែកគិតតែដើរតម្រង់ទៅរកដើមស្រល់ប្រាំដើម ដោយពុំបានយកចិត្តទុកដាក់ថា នៅពីមុខខ្លួនអំបាញ់មិញមានផ្លូវបែកជា២ ។ ផ្លូវមួយស្របតាមឆ្នេរទន្លេ ដែលនៅពីមុខនោះ មូហ្សាផឿកំពុងតម្លើងជំរំចាំទទួលគេ ហើយនៅខាងមុខទៀតនឹងមានស្ពានឆ្លងទន្លេ Bradu (ប្រាឌូ) ទៅកាន់ភូមិអាស់ស្កុល ។ តែដោយស្លុងគំនិតទៅកាន់ដើមស្រល់ប្រាំដើម គ្រែកពុំបានដឹងខ្លួនថា ខ្លួនដើរខុសផ្លូវដែលខ្លួនត្រូវប្រកាន់យកឡើយ ។ នេះជាលើកទី២ ដែលគ្រែកបានវង្វេងផ្លូវម្ដងទៀត ។ គេខំតម្រង់ទៅរកដើមស្រល់ទាំងនោះ ក៏បានជួបប្រទះនឹងចំការក្រូចពោធិ៍សាត់មួយដ៏ធំដែលមានកញ្ជេធំៗផ្ទុកពេញទៅដោយផ្លែក្រូចពោធិ៍សាត់ និងនារីជនជាតិភ្នំកំពុងលុតជង្គង់ក្បែរកញ្ជេនីមួយៗរើស និងរាប់ផ្លែក្រូចដែលកំពុងដាក់ផ្ទាល់នៅលើដីដាក់ទៅក្នុងកញ្ជេ ដោយមានរបៀបរៀបរយ ។

ក្រឡេកឃើញជនបរទេសចំឡែក ពុកមាត់ពុកចង្កាស្រមេមស្រមាម ខោអាវប្រឡាក់ដោយភក់ដី និងធូលី មើលតែសត្វចម្លែក ពួកនារីទាំងនោះក៏នាំគ្នាយកស្បៃបិទមុខតាមរបៀបនារីសាសនាមូស្លីម ហើយនាំគ្នារត់ទៅពួនក្រោយដើមឈើនៃចំការ ។ មានតែក្មេងៗអាយុជាង១០ឆ្នាំឡើងទៅរាប់សិបនាក់រត់ស្រមករកជនបរទេសចម្លែក ដោយខ្លះដឹកដៃ ខ្លះយកដៃមកទះៗលើខ្លួនប្រាណគ្រែក ធ្វើឱ្យធូលីហុយសំពោង ។ នេះជាលើកដំបូងដែលគ្រែក បានគិតអំពីខ្លួនឯង ថាខ្លួនឯងមានសភាពយ៉ាងណា ព្រោះតាំងពីបីខែមកនេះ ខ្លួនបានងូតទឹកតែម្ដងគត់មុនពេលឡើងភ្នំ ។ សក់ក្បាលមហាកខ្វក់ និងដុះវែងធ្លាក់មកលើស្មា ។ គ្រែកបន្ទាបខ្លួនចុះកុំឱ្យខ្ពស់ត្រដែតជាងកូនក្មេងដែលដើរតាមគាត់នោះពេក ។ តែមើលទៅក្មេងទាំងនោះគ្មានការភ័យខ្លាចចំពោះរូបគាត់ឡើយ ។ គាត់ដើរចេញពីចំការក្រូច កាត់តាមវាលស្រែស្រូវសាឡី និងស្រូវ Larley រួចតម្រង់ទៅរកភូមិ ដោយសង្ឃឹមថា ទីនោះជាភូមិអាស់ស្កុល ហើយ មូហ្សាផឿនឹងរង់ចាំគាត់នៅក្បែរជំរំ ដែលមានភ្នក់ភ្លើង ។ តែផ្ទុយទៅវិញ គាត់ពុំបានឃើញនូវអ្វីដែលគាត់ធ្លាប់បានឃើញសោះ ។ មានតាចាស់ម្នាក់សក់ស ពុកមាត់វែង ទឹកមុខស្លូតបូត ឈរនៅចំច្រកចូលភូមិ ។ គាត់ញញឹមមកកាន់គ្រែក ហើយបន្លឺឡើងថា "អាស់សាឡាអាឡៃគុម" (ចូលឱ្យសន្តិភាពចូលមានដល់អ្នក) ។

គាត់ប្រាប់ថា ខ្លួនគាត់ឈ្មោះ ហៃ ជីអាលី មេភូមិកម្ពី ។ គាត់និយាយភាសាបាល់ទី ទើបគ្រែកស្ដាប់យល់ ហើយដឹងខ្លួនថា គេបានវង្វេងផ្លូវម្ដងទៀតហើយ ។ ***(សូមរង់ចាំអានជាបន្តនៅលេខក្រោយ)***

# A.B.C MONEY TRANSACTION, INC

# ក្រុមហ៊ុនផ្ញើប្រាក់ A.B.C



## តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ

| | | ភ្នំពេញ | តាមខេត្ត |
|---|---|---|---|
| ផ្ញើ $100 | យកកម្រៃ | $4.50 | $5.50 |
| $200 | យកកម្រៃ | $9.00 | $11.00 |
| $300 | យកកម្រៃ | $13.50 | $16.50 |
| $500 | យកកម្រៃ | $16.00 | $17.00 |
| $1000 | យកកម្រៃ | $25.00 | $26.00 |
| $1500 | យកកម្រៃ | $35.00 | $36.00 |
| $2000 | យកកម្រៃ | $42.00 | $43.00 |
| $2200 | យកកម្រៃ | $46.00 | $47.00 |

សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

### នៅរដ្ឋ VIRGINIA សូមទាក់ទង

**ABC MONEY TRANSATION ,INC.**

**8 locations to serve you in Virginia**

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

**ARIZONA**
- 4215 N 19th Ave.. Tel : 602.266.6744

**GEOERGIA**
- 4897 Buford Hwy. Ste. 202. Tel: 770.457.7888

**ILLINOIS**
- 4871 N. Broadway . Tel :773.989.7332

**MASSACHUSETTE**
- 996 Dorchester Ave. Tel:617.825.9380
- 1365-1377 Dorchester Ave. -Ste.4,Froor 1 .Tel : 617.265.4600

**MINNESOTA**
- 2718 Nicollet Ave . S.- Ste. 102 B
- Tel : 612.871.4731
- 6350 Brooklyn Blvd . Tel : 763.503.3947

**NORTH CAROLINA**
- 3000 Central Ave. Ste . #9 . Tel : 704-532-4420

**OREGON**
- 6908 N.E. Sandy Blvd . Tel : 503.281.8088

**PHILADFELPHIA**
- 5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794
- 571 Adams Ave . Ave.#4 . Tel : 215.342.6623

**TEXAS**
- 1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461
- 2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817
- 5302 E . Belknap St.- Ste.D6 . Tel : 817.831.4836
- 3538 W . Walnut St. Tel : 972.272.2253
- 11205 Bellaire Blvd . Tel : 281.561.6600
- 10909 Scarsdale Blvd . Tel : 281.481.2700
- 13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

**WASHINTON STATE**
- 766 S.38th St,. Tel : 253.475.2847
- 3818 S.Graham St.-Ste. C Tel : 206.721.2070

Office : 714-590-8740 Fax : 714-590-8776
Cell: 714-603-3509 Toll Free : 1-877-939-0110

### ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

### ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ ( NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS ) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com

តមកទំព័រទី ០១ **នាយកក្រសួងអប់រំនៅហ្វីឡាដែលហ្វៀ...**





លោកស្រី អាគីម៉ាន់ បានសន្យាក្រោមសញ្ញា "ព្រះពុទ្ធបរិនិព្វាន" អាចនឹងធ្វើឱ្យគេយល់បានថា "គឺចាប់ពីពេលនេះតទៅហើយ ដែលព្រះធម៌ ឬចំណេះចាប់ផ្តើមមានការរៀបចំ ហើយផ្សព្វផ្សាយកាន់តែធំឡើងនៅក្នុងសកលលោក" ។

សមាគមខ្មែរតំណាងដោយ រ៉ង ស៊ន បាន ស្នើឱ្យអ្នកស្រី អាគីម៉ាន បង្កើនចំនួនបុគ្គលិកជំនួយភាសាខ្មែរ ឱ្យបានគ្រប់សាលា ដែលមានកូន ខ្មែររៀន ឱ្យបង្កើតការងារដឹកនាំដែលឱ្យមានខ្មែរអាចមានអំណាចសម្រេច...។

សហគមន៍ខ្មែរនាថ្ងៃនោះមានប្រមាណជា ១០០នាក់ ហើយបានរៀបចំឱ្យមានការបង្ហាញសក្ខីកម្មពីបុគ្គលិកសិក្សាពីយុទ្ធជនរងគ្រោះពីសិស្សបោះបង់សាលា... ដើម្បីបង្ហាញក្រសួងអប់រំអំពីភាពជាក់ស្តែងដែលកើតរៀងរាល់ថ្ងៃចំពោះក្រុមគ្រួសារខ្មែរដែលក្រសួងពុំដែលបានចាប់អារម្មណ៍ពីពេលមុនមក។ ខ្មែរកាន់តែច្រើនបានមកគាំទ្រសកម្មភាពអប់រំកូនចៅ ដែលជាសញ្ញាថា "ចំណេះច្បាស់ជានឹងកើនឡើងបើសកម្មភាពរួមសាមគ្គីនេះនៅតែបន្ត" ៕


## FOR SALE BY OWNER

HASS´S AUTO ជួសជុលតួឡានដែលបុកគ្នាម្ចាស់ហាងចូលនិវត្តន៍-ហាងមានដំណើរការ១៧ឆ្នាំមកហើយ -ពាណិជ្ជកម្មមានលំនឹងល្អគ្រប់រដូវលោកអ្នកអាចទិញតែពាណិជ្ជកម្មក៏បាន-ទិញដីជាមួយនឹងផ្ទះក៏បាន -ទិញទាំងពីររួមគ្នាក៏បាន បើចង់ដឹងច្បាស់សូមទូរស័ព្ទរកឈ្មោះ "នីក"

Owner is retiring. 17 years in business at this location. Well established business, all seasons are busy. Option to buy only business, real estate, or both.

Contact Nick: 267-242-7938
615 W. Fisher Ave. Phila, Pa 191203




## FRANK'S TIRES




2624 S. FAIRHILL ST.
(215) 334-2261
OPE N 7 DAYS A WEEK
8 A.M. – 7 P.M.

NEW & USED TIRES
ESTBLISHED SINCE 1984

# បើកថ្មី!

# Grand Opening!

## មជ្ឈមណ្ឌលធ្មេញ វិថីស្នាយឌែ
## Snyder Avenue Dental Center

640 Snyder Avenue
Philadelphia,PA 19148
ទូរស័ព្ទ : 215-334-4900

**THURSDAY, MAY 20th, 2010**
**Rain date, Friday, May 21, 2010**
**11:00am-3:00pm**

មានជូនរង្វាន់-មានភ្លេង និងភេសជ្ជៈ
សំរាប់ទទួលលោកអ្នក
"អញ្ជើញចូលដោយសេរី"



យើងទទួលអ្នកចូលព្យាបាលថ្មី

**South Philadelphia Healthcare Locations :**
- 4th Street Medical Suite: 1401 S.4th St., 4th Floor
- Chinatown Medical Services: 930 Washington Ave.
- Southeast Health Center : 800 Washington Ave
- Wilson Park Medical Center : 2520 Snyder Ave.

ទូរស័ព្ទដោយគ្មានចំណាយសំរាប់ណាត់ជួប
1-888-296-GPHA (4742)
WWW.GPHAIHC.ORG

GPHA Greater Philadelphia Health Action, Inc.

HEALTHCARE THAT MAKES A DIFFERENCE


HONG KONG
SUPERMARKET
FAMER´S BEST
HONG KONG SUPERMARKET
(PA) WEEKLY PROMOTION ITEMS
លក់ចុះថ្លៃពីថ្ងៃ ០៥/០៧_០៥/១៣/២០១០
ON SALE PERIOD
May 05/07-05/13/2010
$9.99/case
Newly Renovated.
Added new section .
Clean and Improved
management !
ទើបនឹងកែលំអរថ្មីឡើងវិញ
-បន្ថែមផ្នែកលក់ថ្មីទៀត
ហាងស្អាត ហើយបង្កើន
គុណភាពគ្រប់គ្រង
Weekly Sale
លក់ចុះថ្លៃរៀងរាល់សប្តាហ៍
2B/ $3.99
99c/can
$3.49/can
79c / LB
79¢/EA
59c/LB
$1.19 / LB
89c / LB
3/$8.99
99c / Btl
3/$1.99/Btl
$1.49/Bag
$3.99 / LB
$3.79/Bag
$2.69/Bag
$4.99 / box
571 ADAMS AVE.PHILADELPHIA,PA19120
Tel: 215-7281300 Fax: 215-728-1600
OPEN
7 DAY
8:00-9:00
•ចំណាយ $140ដុល្លារ ទទួលបានអង្ករស្រូវស ២៥ ផោន
•ចំណាយ $100ដុល្លារ ទទួលបាននូវភេសជ្ជៈ ឬមីកញ្ចប់មួយប្រអប់(តម្លៃ 8.99)
•ចំណាយ $25 ដុល្លារទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។

# ស្ត្រីខ្មែរដំបូងបង្អស់ដែលបានធ្វើដំណើរពីប្រទេសបារាំងមកភ្នំពេញតាមផ្លូវគោក



(តពីលេខមុន)

ដោយ : ពិន នារីពិទូ

ភ្លៀងមិនបានធ្វើឱ្យអ្នកទេសចរណ៍រួញរាក្នុងការទស្សនាប្រាសាទដ៏ប្រណិតនេះទេ ។ នាថ្ងៃរសៀលពួកយើងក៏បានទៅទស្សនាសារៈមន្ទីរនៃរបបកុម្មុយនីស្ត រួមទាំងគំនូរនៃចលនាបដិវត្តន៍ផងដែរ ។ ប្រវត្តិសាស្ត្រនៃសាធារណៈរដ្ឋឆែក Czech ប្រហាក់ប្រហែលនឹងប្រទេសកម្ពុជាយើងដែរ ។ ខ្មែរយើងស្គាល់ប្រទេសនេះដោយសារអតីតប្រធានាធិបតីឆេកូស្លូវ៉ាគី ជាមិត្តរបស់សម្តេចនរោត្តមសីហនុ ធ្លាប់មកធ្វើទស្សនកិច្ចនៅកម្ពុជា ។ ក្រឡេកមើលទៅលើ គឺជានាឡិការប៉ោលយក្សមួយ







យ៉ាងធំ ពួកយើងក៏បានឃើញរូបចំលាក់ព្រះសាវ័កទាំង១២រូបទាំងគ្រោងឆ្អឹងធ្វើចលនានាំឱ្យអ្នកទស្សនាខ្លះភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ បន្ទាប់មកពួកយើងបានដើរមើលចំលាក់នៃសម័យបុរាណ និងដើរតាមផ្លូវ St. Charles Bridge ។ ពួកយើងបានស្រស់ស្រូបអាហារពេលព្រឹកព្រលឹមក្នុងអាហារដ្ឋាននៃសណ្ឋាគារពីព្រោះបន្ទាប់ពីម៉ោង៩ព្រឹកទៅអាហារដ្ឋានមួយនេះនឹងត្រូវបិទទ្វារ ។ ក្រោយមកក៏បានជួបសំណេះសំណាលជាមួយជនជាតិអង់គ្លេសមួយគូរ គឺលោកអេនថូនី ហុបគិន Anthony Hopkins និងប្រពន្ធរបស់គាត់ ។ នាពេលថ្ងៃពួកយើងបានទៅទស្សនាអាគារសាលាក្រុង អ្នកនាំផ្លូវក៏បាននាំយើងឱ្យចូលមើលបន្ទប់ដ៏ធំៗ និងប្រណិតៗរបស់សាលាក្រុង ។

ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៦ : យើងបានចាកចេញពីទីក្រុងប្រាគ Prague នាព្រឹកនេះមេឃស្រឡះល្អ តាមផ្លូវឆ្ពោះទៅប្រទេសប៉ូឡូញ Poland ដោយបើកបររថយន្តហ្សិបបន្តក្នុងចំងាយផ្លូវ២៨២គីឡូម៉ែត្រ ។ នៅទីនោះមានការងាយស្រួលស្វែងរកផ្ទះជួលតូចៗ ក្នុងតំលៃ១២យូរ៉ូក្នុងមួយយប់ ។ នាថ្ងៃរសៀលពួកយើងនាំគ្នាទស្សនាអាគារបុរាណនៃទីក្រុង Wroclaw ដែលជាសំណង់ដ៏ពេញនិយមបំផុតរបស់ជនជាតិអឺរ៉ុបនាសតវត្សន៍ទី១៧ និងសតវត្សរ៍ទី១៨ ។ បន្ទាប់មកពួកយើងក៏បានចេញដំណើរពីទីក្រុង Wroclaw ទៅទីក្រុង Lodz និងឆ្ពោះទៅទីក្រុងវ៉ាសូវី Warsaw ដែលមានចំងាយផ្លូវ២៣៧គីឡូម៉ែត្រ ដោយទៅដល់ទីនោះនៅម៉ោង៤ និង ៤០នាទី ។ Lodz គឺជាទីក្រុងលំដាប់ទីពីររបស់ប្រទេសប៉ូឡូញ Poland ដែលរីកចំរើនខាងឧស្សាហកម្មតម្បាញក្រណាត់ និងផលិតកម្មភាពយន្ត ។

ពួកយើងបានចាកចេញពីទីក្រុង Lodz នៃប្រទេសប៉ូឡូញ ឆ្ពោះទៅទីក្រុងវ៉ាសូវី Warsaw បើកបរក្នុងចំងាយផ្លូវ១៧០គីឡូម៉ែត្រ ក្នុងរយៈពេលបីម៉ោង ។ នៅប៉ូឡូញពិសេសតាមជនបទនៃអឺរ៉ុបកណ្តាល ពុំសូវមានផ្លាកសញ្ញាបង្ហាញផ្លូវច្បាស់លាស់ និងច្រើនដូចនៅអឺរ៉ុបខាងលិចទេ ម្លោះហើយ ស៊ីលវីយ៉ា Sylvia និងអូរេលី Aurélie ត្រូវចែកការណ៍គ្នាធ្វើ ម្នាក់កំពុងបើកបរយ៉ាងយកចិត្តទុកដាក់ និងម្នាក់ទៀតត្រូវមើលផែនទី សំណាងល្អបានរកឃើញផ្លូវឆ្ពោះទៅមុខដោយសុវត្ថិភាព ។ នាថ្ងៃរសៀលក្នុងទីក្រុងដ៏ល្បីល្បាញដែលខ្មែរយើងធ្លាប់ស្គាល់ថាជា "ទីក្រុងវ៉ាសូវី" នោះយើងក៏បានដើរទស្សនាអាគារបែបបុរាណ ដែលមានលំនាំដូចគ្នាគឺតំបន់ Stare Miasto district ពេលល្ងាចទៅភ្លក់រស់ជាតិម្ហូប Pieczarkami Bulka ដែលជាម្ហូបពេញនិយមរបស់ជនជាតិប៉ូឡូញ Poland ។

អស់រយៈពីរសប្តាហ៍បន្ទាប់ពីធ្វើដំណើរឆ្លងកាត់តាម ហ្សូរីក (Zurich), មុយនីក (Munich), សាលស្ប៊ឺ (Salzburg), ប្រាគ (Prague) និង វ៉ាកសូវី (Warsaw) នាពាក់កណ្តាលខែសីហា យើងបានមកដល់សាធារណៈរដ្ឋ បេឡារីស (Belarus) ដែលស្ថិតនៅក្នុងអឺរ៉ុបភាគខាងកើតមានព្រំប្រទល់ខាងជើង




ឈាងខាងកើតជាប់នឹងប្រទេសរុស្សី (Russia) ខាងត្បូងជាប់ និងអ៊ុយក្រែន (Ukraine) ខាងលិចជាប់នឹងប្រទេស ប៉ូឡូញ (Poland) និងខាងជើងភាគខាងលិចជាប់នឹង Lithuania និង Latvia ។ រាជធានីសំខាន់របស់រដ្ឋនេះឈ្មោះ មីង (Minsk) រួមទាំងក្រុងសំខាន់ៗមួយចំនួនទៀតដូចជា ប្រែស (Brest), គ្រូដណូ (Grodno), គូមែល (Gomel), មូគីលីវ (Mogilev) និងវីកិប (Vitebsk) ។

ស្ថិតក្នុងទីក្រុង ប្រែស (Brest) នាពេលល្ងាចយើងក៏សំរេចចិត្តបរិភោគអាហារនៅភោជនីយដ្ឋានយូល វែល (Jules Verne) ដោយចំណាយអស់ប្រហែល១០យូរ៉ូសំរាប់អាហារពេលល្ងាច ។ ថ្ងៃបន្ទាប់មកយើងបានទៅការិយាល័យទេសចរណ៍នៃទីក្រុងប្រែស (Brest) ប៉ុន្តែការិយាល័យនេះបានឈប់សំរាកនៅថ្ងៃអាទិត្យធ្វើឱ្យយើងមិនអាចទៅទស្សនានៅឧទ្យានជាតិ បាឡាវិចកេតា ពូជ Belavejskaia Poutch) ដែលមានចំងាយ៦០គីឡូម៉ែត្រពីទីក្រុង ។ ភាសាផ្លូវការរបស់រដ្ឋនេះគឺភាសារុស្សី (Russian) និងភាសាជនជាតិដើម បាឡារាន (Belarusian) ហេតុដូចនេះហើយ នៅលើឈ្មោះផ្លូវនីមួយៗត្រូវបានសរសេរជាអក្សរដើមរបស់ប្រទេសនេះប្រសិនជាយើងមិនស្គាល់ឈ្មោះផ្លូវច្បាស់លាស់ និងមិនមានការអនុញ្ញាតពីអជ្ញាធរណាមួយទេនោះ មិនគួរប្រថុយប្រថានក្នុងការដើរទស្សនាទីក្រុងនេះតែម្នាក់ឯង ទោះបីជាតំបន់អស់ទាំងនេះលែងជាតំបន់កុម្មុយនិស្តហើយក្តី តែភាពតឹងតែងនៅតែមានដដែលនៅឡើយ ។ យើងបានទៅដល់បន្ទាយប្រែស (Brest) ក្នុងចំងាយផ្លូវ២ម៉ាយ ក្រោមមេឃដ៏ខៀវល្វឹងល្វើយទីនោះមានទីធ្លាធំ និងសំបូរដោយរូបចំលាក់ជាច្រើនគួរឱ្យចាប់ចិត្ត ។ នាពេលរសៀលយើងបានទស្សនារូបចំលាក់លេនីន (តទៅលេខក្រោយ)

NEW PHNOM PENH RESTAURANT
○មីបំពងគ្រឿងសមុទ្រ ○គុយទាវគោក -គុយទាវសាច់គោ
○ផាត់ថៃ ○ឡុកឡាក់ ○មាន់ឆាខ្ញី
○បាយសាច់ជ្រូកអាំង ○មីកន្ត្រាំងសាច់គោ ○បាយឆាសាច់គ្រប់មុខ



TEL.(215) 389-2122
2301 South. 7th Street. Philadelphia, PA 19148
( 7th & Wolf)

Sav-Mor PHARMACY Tel: 215-467-1220
ឱសថស្ថានខ្មែរ
Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447



បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត
▸▸Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
▸▸យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ
*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.

# NEW GOLDEN PALACE

**SEAFOOD RESTAURANT**
**801-21 Washington Avenue.**
**Philadelphia, Pa 19147**

**Tel: 215-627-2822**

Business Hours: Monday–Sunday. 10 a.m.--10 p.m.

## សូមអញ្ជើញគ្រោងពិធីរបស់លោកអ្នកជាមួយនឹងយើងខ្ញុំ

*Plan your next event here!*



| | |
|---|---|
| • *Wedding Reception* | •ពិធីមង្គលការ |
| • *Birthday Parties* | •បុណ្យខួបកំណើត |
| • *Business Meetings* | •ប្រជុំការងារជំនួញ |
| • *Private Parties* | •ពិធីជប់លៀងជាឯកជន |
| • *Fundraisers* | •បុណ្យរៃអង្គាសប្រាក់ |
| • *We Accept Reservation for Holidays* | •យើងទទួលឱ្យកក់កន្លែងធ្វើពិធីនៅថ្ងៃឈប់បុណ្យទានបាន |

## យើងបំរើម្ហូប ឌិម ស៊ុម រាល់ថ្ងៃ ពីព្រឹកដល់ល្ងាច



**We Serve Dim Sum Daily All Day Long &**



**Also Try Our Vietnamese Phở**

កុំភ្លេច ភ្លក់ "ហ្វើ" វៀតណាមរបស់យើង

**From 10 a.m. – 10 p.m.**

## ពិធីជប់លៀងល្ងាចពិសេស ជាមួយក្រុមគ្រួសារ

**ROYAL FAMILY DINNER PACKAGE**

សំរាប់៦នាក់-ម្ហូប៧មុខ- **$78**
**DINNER FOR 6 - 7 Entrées $78**



1. **Vietnamese Spring Roll**
2. **Sweet Sour Pork Chops**
3. **Seafood Bean Curd Soup**
4. **Lobster with Ginger & Scallion**
5. **Steam Fish**
6. **House Special Fried Rice**
7. **Seasonal Fruit**

សំរាប់៨នាក់-ម្ហូប៨មុខ- **$98**
**DINNER 8 – 8 Entrées $98**

1. **Palace Appetizer**
2. **Shrimp Hot & Sour Soup**
3. **Baby Claims with Black Bean Sauce**
4. **Sautéed seafood with Chinese Vegetables**
5. **Lobster with Ginger & Scallion**
6. **Steam Fish**
7. **House Special Lo Mein**
8. **Seasonal Fruit**

សំរាប់១០នាក់-ម្ហូប៩មុខ- **$128**
**DINNER 10 – 9 Entrées $128**

1. **Fried Shrimp Rolls**
2. **Salt Baked Shrimp**
3. **Seafood with Sweet Corn Soup**
4. **Seafood Bird's Nest**
5. **Crispy Fried Chicken**
6. **Double Lobsters with Ginger Scallion**
7. **Steam/Fried Fish Tilapia**
8. **House Special Fried Rice**
9. **Seasonal Fruit**

# COMPUTER+ LLC

SURVEILLANCE SYSTEM, COMPUTER RETAILER, REPAIR & SERVICES

ជំនាញការខាងផ្គុំសាងកុំព្យូទ័រ លក់គ្រឿងកុំព្យូទ័រ
និងដាក់គ្រឿងថតវីដេអូសំរាប់ការពារសន្តិសុខ

REMOTE VIEWING

Remote Monitoring, Recording, Controlling through Internet from *anywhere* at *anytime*



*Stand-Alone System*



*PC-Base System*






*HOME or VACATION*



On the ROAD

5709 N. 5th St., Phila, PA 19120 Open: *Mon-Sat; 10am—6:00pm*
*Peter Hong Ching* * Tel: (215) 276-7000 * Fax: (215) 276-7001
E-mail: peterchng_99@yahoo.com www.computerplusllc.com

# Nationwide

Insurance & Financial Service

## សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ

We offer Cheap Price for Every Client

## យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃទាប

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញឈ្មួញ |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រងសុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

**Discount 30% when you purchase Home & Auto Insurance**

ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ
ធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8 Philadelphia, PA 19147
Tel: (215) 463-1257 ; Fax: (215) 463-2036

ឌឹ ខេមបូឌា ដេលី The Cambodia Daily

# Request for Screening of Chea Vichea Film Rejected by City

By Yun Samean
THE CAMBODIA DAILY

Phnom Penh Municipal Governor Kep Chuktema has rejected a request from the Cambodian Confederation of Unions to screen the documentary film "Who Killed Chea Vichea?" as part of their International Labor Day activities this Saturday.

Mr Chuktema's rejection came after a meeting between CCU President Rong Chhun yesterday morning, where the screening of the film and the CCU's Labor Day march were discussed.

In a further blow to its Labor Day activities, Mr Chhun said that Mr Chuktema requested yesterday that the CCU merge its march with that of the rival Cambodian Labor Confederation.

The CCU planned to screen the film on Saturday afternoon near the newspaper stand where then-Free Trade Union president Chea Vichea was assassinated in 2004.

"Concerning the film 'Who Killed Chea Vichea?' Phnom Penh Municipality doesn't give permission because this film has not been given a license from relevant ministries," Mr Chuktema wrote in a letter he handed to Mr Chhun at yesterday's meeting.

Despite the rejections, Mr Chhun said that up to 200 CCU members will press on with their planned Labor Day march and the film screening, regardless of the authorities' requests.

"We still have the same stand.... We will continue to proceed [with] the plan as scheduled," Mr Chhun said.

"The film does not affect the government leaders—it tells about Chea Vichea's murder."

A last minute reprieve to show the film, however, may still be granted to the CCU by Minister of the Interior Sar Kheng, according to the ministry's spokesman Lieutenant General Khieu Sopheak.

Mr Sopheak said the Interior Ministry had not yet received correspondence from City Hall about the CCU's planned activities, so the ministry has not yet made a final decision about the screening of the film.

"When we get it, it will be up to my boss," Mr Sopheak said, adding that the authorities would be forced to uphold the law if the CCU pushes ahead with its screening without permission.

"If they abuse the law, we will enforce the law," he said.

Though Mr Chhun said he was not willing to merge his group's march with any other organization, CLC President Ath Thorn said yesterday that the CCU was welcome to join the estimated 7,000 workers who will be marching under the banner of the CLC on Saturday.

"If we merge the march, we will have the same message," Mr Thorn said.

The SRP said in a statement yesterday that party members will march alongside CCU members, supporting the confederation's call for improved rights for workers.

"We will participate in the march to show support for the workers," SRP lawmaker and spokesman Yim Sovann said, adding that SRP members will also join workers at the screening of "Who Killed Chea Vichea?"

Kong Kantara, Ministry of Culture undersecretary of state, said the creators of "Who Killed Chea Vichea?" had not sought a license from the ministry, meaning it would be illegal to screen the film in public.

According to Sub Decree 63, signed by Prime Minister Hun Sen on Sept 4, 2000, all films must receive a license before being screened in public, he said.

# សំណើរសុំបញ្ចាំងភាពយន្តរឿងសម្លាប់លោក ជា វិជ្ជា ត្រូវបានសាលាក្រុងបដិសេធ

ដោយ : យន់ សាមៀន

The Cambodia daily




លោក កែប ជុតិមា អភិបាលក្រុងភ្នំពេញ បានច្រានចោលសំណើររបស់សហព័ន្ធសហជីពកម្ពុជា ដើម្បីបញ្ចាំងខ្សែភាពយន្តឯកសាររឿង "នរណាសម្លាប់ ជា វិជ្ជា?" ជាផ្នែកមួយនៃសកម្មភាពនៅទិវាពលកម្មអន្តរជាតិរបស់ខ្លួននៅថ្ងៃសៅរ៍នេះ ។

ការច្រានចោលរបស់លោក កែប ជុតិមា បានកើតមានឡើងក្រោយពីកិច្ចប្រជុំមួយរវាងលោក រ៉ុង ឈុន ប្រធានសហព័ន្ធសហជីពកម្ពុជាកាលពីព្រឹកម្សិលមិញ ជាទីដែលការប្រឆាំងភាពយន្តនិងការដើរក្បួននៅទិវាពលកម្មអន្តរជាតិរបស់សហព័ន្ធសហជីពត្រូវបានពិភាក្សា ។

ជាការសំពងបន្ថែមទៅលើសកម្មភាពនៅទិវាពលកម្មអន្តរជាតិរបស់ខ្លួននោះលោក រ៉ុង ឈុន បានមានប្រសាសន៍ថា លោក កែប ជុតិមា បានស្នើកាលពីម្សិលមិញឱ្យសហព័ន្ធសហជីពកម្ពុជា បញ្ចូលការដើរក្បួនរបស់ខ្លួនជាមួយនឹងការដើរក្បួនរបស់សហព័ន្ធការងារកម្ពុជាដែលជាគូប្រឆាំងតែមួយ ។

សហព័ន្ធសហជីពកម្ពុជា គ្រោងបញ្ចាំងខ្សែភាពយន្តនេះនៅរសៀលថ្ងៃសៅរ៍ នៅជិតតូបកាសែត ជាទីដែលលោក ជា វិជ្ជា ប្រធានសហជីពសេរីកម្មករ នៅពេលនោះ ត្រូវបានគេធ្វើឃាតកាលពីឆ្នាំ២០០៤ ។

លោក កែប ជុតិមា មានសរសេរនៅក្នុងលិខិតមួយដែលលោកបានឱ្យទៅលោក រ៉ុង ឈុន នៅឯកិច្ចប្រជុំកាលពីម្សិលមិញថា "ពាក់ព័ន្ធនឹងខ្សែភាពយន្តរឿង "នរណាសម្លាប់ ជា វិជ្ជា?" សាលាក្រុងភ្នំពេញ មិនផ្តល់ការអនុញ្ញាតឱ្យទេ ពីព្រោះភាពយន្តនេះមិនបានទទួលអាជ្ញាប័ណ្ណពីក្រសួងពាក់ព័ន្ធឡើយ" ។

ថ្វីបើមានការច្រានចោលនេះក៏ដោយ ក៏លោក រ៉ុង ឈុន បានមានប្រសាសន៍ដែរថា សមាជិកចំនួន២០០នាក់របស់សហព័ន្ធសហជីពកម្ពុជានឹងបន្តការដើរក្បួននៃទិវាពលកម្មអន្តរជាតិ និងបញ្ចាំងភាពយន្តនេះដូចដែលបានគ្រោងដែរ ដោយមិនគិតអំពីសំណើររបស់អាជ្ញាធរឡើយ ។

លោក រ៉ុង ឈុន បានមានប្រសាសន៍ថា "យើងនៅតែមានជំហរដដែល... យើងនឹងបន្តដំណើរការទៅមុខជាមួយនឹងផែនការនេះដូចដែលបានគម្រោងទុក" ។"ភាពយន្តនេះមិនធ្វើឱ្យប៉ះពាល់ដល់មេដឹកនាំរដ្ឋាភិបាលឡើយវានិយាយអំពីឃាតកម្មសម្លាប់ លោក ជា វិជ្ជា" ។

យោងតាមលោកឧត្តមសេនីយ៍ឯក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃបានឱ្យដឹងថា ទោះជាយ៉ាងណា ការសម្រេចនៅទីចុងក្រោយឱ្យបញ្ចាំងភាពយន្តនេះ ប្រហែលជាអាចត្រូវលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃចេញដល់សហព័ន្ធសហជីពកម្ពុជា ។

លោក ខៀវ សុភ័គ បានមានប្រសាសន៍ថា ក្រសួងមហាផ្ទៃមិនទាន់បានទទួលការឆ្លើយតបពីសាលាក្រុងអំពីសកម្មភាពដែលបានគ្រោងទុករបស់សហព័ន្ធសហជីពកម្ពុជា នេះទេ ដូច្នេះក្រសួងមិនទាន់ធ្វើសេចក្តីសម្រេចចុងក្រោយពីការបញ្ចាំងភាពយន្តនេះទេ ។

លោក ខៀវ សុភ័គ បានមានប្រសាសន៍ថា "នៅពេលដែលយើងបានទទួលការឆ្លើយតប វាអាស្រ័យលើចៅហ្វាយរបស់ខ្ញុំ" ។ លោកបានបន្ថែមថា អាជ្ញាធរនឹងបង្ខំចិត្តធ្វើតាមច្បាប់ ប្រសិនបើសហព័ន្ធសហជីពកម្ពុជាដំណើរការបញ្ចាំងភាពយន្តរបស់ខ្លួនដោយគ្មានការអនុញ្ញាត ។ លោកបានមានប្រសាសន៍ថា "ប្រសិនបើពួកគេបំពានច្បាប់យើងនឹងអនុវត្តច្បាប់" ។

ទោះជាលោក រ៉ុង ឈុន មានប្រសាសន៍ថា លោកគ្មានបំណងបញ្ចូលការដើរក្បួនរបស់ក្រុមលោកជាមួយសហជីពផ្សេងទៀតក៏ដោយ ក៏លោក អាត់ ធន ប្រធានសហព័ន្ធពលកម្មកម្ពុជា ក៏បានមានប្រសាសន៍កាលពីម្សិលមិញដែរថា សហព័ន្ធសហជីពកម្ពុជា ត្រូវបានស្វាគមន៍ឱ្យចូលរួមជាមួយកម្មករប្រមាណ៧.០០០នាក់ ដែលនឹងដើរក្បួនក្រោមបដារបស់សហព័ន្ធពលកម្មកម្ពុជានៅថ្ងៃសៅរ៍ ។

លោក អាត់ ធន បានមានប្រសាសន៍ថា "ប្រសិនបើយើងបញ្ចូលការដើរក្បួននេះបញ្ចូលគ្នា យើងនឹងមានសារដូចគ្នា" ។

គណបក្ស សម រង្ស៊ី បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយកាលពីម្សិលមិញថា ក្រុមសមាជិកគណបក្សនឹងដើរក្បួនជាមួយសមាជិករបស់សហព័ន្ធសហជីពកម្ពុជា ដោយគាំទ្រការអំពាវនាវរបស់សហព័ន្ធឱ្យមានការធ្វើឱ្យប្រសើរឡើងដល់សិទ្ធិរបស់កម្មករ ។

លោក យឹម សុវណ្ណ សមាជិកសភា និងជាអ្នកនាំពាក្យរបស់គណបក្ស សម រង្ស៊ី បានមានប្រសាសន៍ថា "យើងនឹងចូលរួមនៅក្នុងការដើរក្បួននេះ ដើម្បីបង្ហាញការគាំទ្រចំពោះកម្មករ" ។ លោកបានបន្ថែមថា សមាជិកគណបក្ស សម រង្ស៊ី ក៏នឹងចូលរួមជាមួយកម្មករនៅកន្លែងបញ្ចាំងភាពយន្ត "នរណាសម្លាប់ ជា វិជ្ជា?" នេះដែរ" ។

លោក គង់ កានតាណា អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ បានមានប្រសាសន៍ថា អ្នកផលិតភាពយន្តរឿង "នរណាសម្លាប់ ជា វិជ្ជា?" មិនទាន់បានស្វែងរកអាជ្ញាប័ណ្ណពីក្រសួងទេ មានន័យថា វានឹងជាការខុសច្បាប់ក្នុងការបញ្ចាំងភាពយន្តនោះជាសាធារណៈ ។

លោកបានមានប្រសាសន៍ថា យោងតាមអនុក្រឹត្យលេខ៦៣ ដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចុះហត្ថលេខាកាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០០ ខ្សែភាពយន្តទាំងអស់ត្រូវតែមានអាជ្ញាប័ណ្ណមុនពេលដាក់បញ្ចាំងជាសាធារណៈ ៕

# *Livelihoods But Not Lives Lost in K Speu Market Blaze*

By Cheng Sokhorng
THE CAMBODIA DAILY

A fire in Kompong Speu province's Odong district on Wednesday evening blazed through and destroyed 168 stalls in Kraing Chek market and burned 12 houses to the ground, according to police and market vendors.

No one was injured in the fire, which started at 7:20 pm and lasted about 20 minutes, district police chief Khoem Samorn said yesterday.

"The first reason was a technical error with the connection which caused the electric wires to explode," he said, adding that firefighters were unable to reach the fire in time because the Kraing Chek commune market is 20 km from the fire station and difficult to reach by road.

Vendors were unable to save any of their merchandise and will have to rely on assistance from the Cambodian Red Cross and individual donors for help, Mr Samorn said.

Market vendor Pheng Lan, 40, said that he blamed firefighters for not extinguishing the fire, which destroyed around $10,000 worth of goods.

"I saw fire trucks do nothing to put out the fire," Mr Lan said.

Vendor Ngoub Chariya, 40, also said that the fire trucks came late and firefighters were careless in their work.

"If fire trucks respond like this, I prefer not to have any fire trucks at all," Mr Chariya said.

# អគ្គីភ័យឆេះតូបអស់១៦៨តូបនៅក្នុងផ្សារក្រាំងចេកក្នុងខេត្តកំពង់ស្ពឺ

ដោយ : ចេង សុខហ៊ង

The Cambodia daily

យោងតាមនគរបាល និងក្រុមអាជីវករក្នុងផ្សារបានឱ្យដឹងថា អគ្គីភ័យនៅក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីល្ងាចថ្ងៃពុធ បានឆាបឆេះនិងបំផ្លាញតូបអស់ចំនួន១៦៨តូប នៅក្នុងផ្សារក្រាំងចេក និងឆេះផ្ទះដួលរាបដល់ដីអស់១២ខ្នង ។

លោក ខឹម សាម៉ន អធិការនគរបាលស្រុក បានមានប្រសាសន៍កាលពីម្សិលមិញថា គ្មាននរណាម្នាក់រងរបួសនៅក្នុងអគ្គីភ័យ ដែលបានចាប់ផ្តើមឆេះនៅម៉ោង៧:២០នាទីល្ងាច និងបានឆេះអស់រយៈពេលប្រហែល២០នាទីនោះទេ ។

លោកបានមានប្រសាសន៍ថា "ហេតុផលទីមួយ គឺកំហុសផ្នែកបច្ចេកទេសជាមួយនឹងការតខ្សែភ្លើង ដែលបានបណ្តាលឱ្យខ្សែភ្លើងផ្ទុះ" ។ លោកបានបន្ថែមថា អ្នកពន្លត់អគ្គីភ័យមិនអាចមកដល់អគ្គីភ័យនេះទាន់ពេលទេ ពីព្រោះផ្សារនៅក្នុងឃុំក្រាំងចេកនេះមានចម្ងាយ២០គីឡូម៉ែត្រពីកន្លែងអគ្គីភ័យនេះ និងផ្លូវពិបាកចូលទៀតផង ។

លោក ខឹម សាម៉ន បានមានប្រសាសន៍ថា ក្រុមអាជីវករមិនអាចសង្គ្រោះយកទំនិញរបស់ពួកគេបានខ្លះទេ ហើយនឹងត្រូវពឹងផ្អែកលើជំនួយពីកាកបាទក្រហមកម្ពុជា និងអ្នកផ្តល់ជំនួយជាលក្ខណៈបុគ្គលសម្រាប់ជួយ ។

អាជីវករក្នុងផ្សារឈ្មោះ ផេង ឡាន អាយុ៤០ឆ្នាំ បានមានប្រសាសន៍ថា គាត់បានបន្ទោសក្រុមពន្លត់អគ្គីភ័យចំពោះការមិនពន្លត់អគ្គីភ័យនេះ ដែលបានបំផ្លាញទំនិញដែលគិតជាទឹកប្រាក់អស់ប្រហែល១០.០០០ដុល្លារ ។ លោក ផេង ឡាន បានមានប្រសាសន៍ថា "ខ្ញុំបានឃើញថា រថយន្តអគ្គីភ័យមិនបានពន្លត់អគ្គីភ័យនេះទេ " ។

អាជីវករឈ្មោះ ងួប ចរិយា អាយុ៤០ឆ្នាំ ក៏បានមានប្រសាសន៍ដែរថា រថយន្តពន្លត់អគ្គីភ័យទាំងនេះមកយឺត ហើយក្រុមអ្នកពន្លត់អគ្គីភ័យមានការធ្វេសប្រហែសនៅក្នុងកិច្ចការរបស់ពួកគេ ។

លោក ចរិយា បានមានប្រសាសន៍ថា "ប្រសិនបើរថយន្តពន្លត់អគ្គីភ័យឆ្លើយតបដូចនេះ ខ្ញុំមិនចង់ឱ្យមានរថយន្តពន្លត់អគ្គីភ័យណាមួយទាល់តែសោះ" ៕

# អាថ៌កំបាំង និងសិល្បៈនៃជីវិត
# SECRET AND ART OF LIVING



(តមកពីលេខមុន)

រៀបរៀងដោយ
លោក ម៉ៅ ច័ន្ទសំណុំ

ឧទាហរណ៍ : ពេលដេកលក់មានមូសមកខាំ ជាស្វ័យប្រវត្តិដៃលូកមកទះដោយយើងជាម្ចាស់ខ្លួនពុំបានដឹងឡើយ ។ គួរកត់សំគាល់ថា ចរន្តគំនិតដែលហូរចេញមកនេះ ពុំមានជាកម្មសិទ្ធិរបស់យើងផ្ទាល់ខ្លួនឡើយ វាមានប្រភពពីម៉េម៉ូរី ដែលផ្តិតបន្តមកពីសង្គមខាងក្រៅខ្លួនឯណោះទេ ។ យើងគ្រប់គ្នាតែងគិតដោយភ័ន្តច្រឡំដោយអវិជ្ជា (Ignorance) ថា "ខ្ញុំជាអ្នកគិត ខ្ញុំជាមេគំនិត" តាមពិតសង្គមដាក់ពុម្ព ឬបញ្ជាឱ្យយើងគ្រប់រូបគិតដូច្នេះ ។ យើងគ្មានសេរីភាពនឹងគិតដោយខ្លួនឯងឡើយ ។ ឧទាហរណ៍ ទស្សនាទានកុម្មុយនិស្ដដំបូងឡើយចេញពីមនុស្សមួយក្រុមហើយ កើតជាសមូហគំនិត Collective thoughts ឬរលកគំនិតនៅក្នុងលំហអាកាស បន្ទាប់មកវាបានជ្រាបចូលទៅក្នុងម៉េម៉ូរីអ្នកដឹកនាំប្រទេសនានា ហើយបានចេញមកក្រៅជាការប្រព្រឹត្តជាក់ស្តែង នាំមកនូវវិនាសកម្មជាប្រវត្តិសាស្ត្រគួរឱ្យរន្ធត់តក់ស្លុតបំផុត ។

យើងអាចសន្និដ្ឋានថា លំហូរគំនិតដែលលេចមកខួរក្បាលមនុស្ស ហើយបន្តចេញជារលកប្រតិកម្មជារលកមនោសញ្ចេតនាជាពាក្យសំដី ជាសកម្មភាពខាងក្រៅ មានប្រភពមកពីបន្ទប់ម៉េម៉ូរី ។ អត្ថន័យនេះ យើងអាចនិយាយម្យ៉ាងទៀតថា លំហូរគំនិតទាំងនោះ ទទួលឥទ្ធិពលពីបន្ទប់ម៉េម៉ូរីពីអតីតកាល Human mind or flow of thoughts are conditioned by his own past experiences, this is the conditioning phenomenon in human being. ។

បាតុភូតទទួលឥទ្ធិពលពីម៉េម៉ូរីមកនេះ ក្នុងភាសាទំនើបសព្វថ្ងៃ ហៅថា អសតិ Unconscious mind មានន័យម្យ៉ាងទៀតថា មនុស្សយើងធ្វើសកម្មភាពសព្វយ៉ាងដោយពុំដឹងខ្លួន Unconscious យើងគ្មានសេរីភាពនឹងសំរេចអ្វីៗដោយខ្លួនយើងឡើយ យើងមានម្ចាស់ពីក្នុងបញ្ជាមកឱ្យគិតឃើញយ៉ាងនេះ ឬបែបនោះជាព្រហ្មលិខិតកំណត់ Destiny ។

**ត តើចំនួនគំនិតប៉ុន្មានឆ្លងកាត់ខួរក្បាលដ៏តូចនេះ?**

អ្នកប្រាជ្ញវិទ្យាសាស្ត្របានរកឃើញថា ក្នុង២៤ម៉ោង ខួរក្បាលមនុស្សយើងដ៏តូចនេះ ត្រូវបានឆ្លងកាត់លំហូរគំនិតចំនួន៦០០០០ ពីម៉េម៉ូរីមក ។ ចំនួននេះហួសអំពីតម្រូវការចាំបាច់នៅជីវិតរស់នៅ ។ ធម្មតាមនុស្សម្នាក់ៗ ត្រូវការតែប្រមាណជា៣%នៃ ៦០០០០គំនិតនោះប៉ុណ្ណោះ សំរាប់ការរស់នៅជាក់ស្តែង ចំណែកឯ៩៧%ទៀត សុទ្ធតែជាសំរាមឥតបានការនាំមកនូវការរំខានគ្មានឈប់ឈរ ។ គួរឱ្យអភ័ព្វយើងជាម្ចាស់ខ្លួន គ្មានសិទ្ធិនឹងទប់ស្កាត់ចលនាលំហូរគំនិតនេះឡើយ វាជ្រៀតចូលមកក្នុងខួរក្បាលពុំមានការហៅរកឡើយ ។ បាតុភូតខ្មៅងងឹត និងអវិជ្ជមាននេះនាំមកនូវផលវិបាក :




ចិត្តមនុស្សត្រូវកើតកកល្អក់ ប្រាជ្ញាចុះអន់ថយជាលំដាប់ជាមួយការកើននៃអាយុ ។ យើងធ្លាប់សំគាល់ឃើញថា មនុស្សកាន់តែចាស់កាន់តែរអ៊ូរទាំ ។ អ្នកខ្លះនិយាយចេញមកក្រៅម្នាក់ឯងរង្វេៗ មិនចេះចប់ ។ បាតុភូតនិយាយម្នាក់ឯង Self talk ក្នុងក្បាលយើងម្នាក់ៗ ហូរដូចទឹក ។ សភាពនេះកើតមានក្នុងខួរក្បាលគ្រប់គ្នា គ្រាន់តែមិនចេញមកក្រៅប៉ុណ្ណោះ Voice in the head ។ នេះជាជំងឺរ៉ាំរ៉ៃមើលពុំជា ដែលយើងម្នាក់ៗមានជាប់នឹងខ្លួនជាអ្នករងគ្រោះរហូតដល់ស្លាប់ ។ ព្រះពុទ្ធលោកមានឱសថដ៏សក្តិសិទ្ធិសំរាប់ព្យាបាលជម្ងឺរបស់មនុស្សជាតិនេះ ។ សូមអានបន្តលោកអ្នកនឹងបានដឹងអំពីរឿងនេះ ជាប្រយោជន៍ផ្ទាល់ខ្លួនពុំខានឡើយ ។

មនុស្សយើង ទោះបីគេឱ្យសំរាកក៏ពុំបានសំរាក ព្រោះលំហូរគំនិតនេះ ។ ម្យ៉ាងទៀតគំនិតនីមួយៗ សុទ្ធតែបង្កជារូបភាពនៃការប្រើប្រាស់ថាមពលពីក្នុងខ្លួនមក ។ ដូច្នោះថាមពលមួយភាគធំត្រូវបញ្ចេញចោលដោយខ្ជះខ្ជាយ តាមរូបភាពលំហូរគំនិតនេះ ។ បើនរណាម្នាក់ពុំបានដេកមួយ ឬពីរយប់នោះ គេនឹងធេងធោង ហេវហត់ ខ្សោះខ្លួនពុំខានឡើយ ។

បន្ទប់ម៉េម៉ូរីបង្កប់ទាំងរឿងល្អ ទាំងរឿងអាក្រក់តាមល័ក្ខខ័ណ្ឌនៃជីវិតយើងម្នាក់ឆ្លងកាត់កន្លងមក ។ ជូនកាលវាបញ្ចេញសំណុំរឿងល្អមក អនុស្សាវរីយ៍ជាទីពេញចិត្ត ឃើញពិសោធន៍ ឃើញភាពសប្បាយរីករាយ ។ ជូនវាខ្ទាក់រឿងរ៉ាវអាស្រូវពីអតីតកាលយើងពិសោធន៍នូវភាពជូរចត់ កំហឹង ភ័យ តំនុំច្រណែន ព្រួយបារម្ភ រំជួលចិត្ត ។ល។ រូបភាពទាំងមូលប្រែក្លាយទៅជាញាប់ញ័រ បេះដូងដើរញាប់ខុសធម្មតា តឹងទ្រូង ។ល។និង។ល។ អ្នកខ្លះបង្កប់ក្នុងម៉េម៉ូរី អនុស្សាវរីយ៍ខ្មៅងងឹត អាស្រូវ អាក្រក់ហួសវិស័យដូចជា ខ្មែរយើងជួបប្រទះនឹងពិសោធន៍ជីវិតក្នុងរបប ប៉ុល ពត យង់ឃ្នង/ក្មេងស្រីទទួលរងគ្រោះដោយត្រូវចាប់រំលោភយ៉ាងព្រៃផ្សៃ/រឿងឃាតកម្មដ៏តក់ស្លុត ។ល។ រឿងរ៉ាវអាស្រូវទាំងអស់នោះ ក្អែរចេញមកក្រៅមួយថ្ងៃដប់ ឬម្ភៃដង អ្នករងគ្រោះត្រូវចាប់ឃុំក្នុងគុកងងឹតនៃផ្លូវចិត្ត គ្មានច្រកចេញ ។ ដំបូងជាជំងឺផ្លូវចិត្ត ។ នេះជាពិលពុលបង្កប់នៅក្នុងខ្លួនជនរងគ្រោះ Psychological poison ។ ចំពោះយើងជាមនុស្សធម្មតា ក៏មានរឿងបែបនេះកើតមានច្រើនដែរ ប៉ុន្តែយើងសាំហើយ ចាត់ទុកថាជារឿងធម្មតាទៅវិញ ។ (តទៅលេខក្រោយ)

**ANGKOR AUTO SERVICE, INC.**

**ហាងជួសជុលរថយន្ត "អង្គរ"**

4835 N. 16th Street. Tel : (215) 455-7810
Philadelphia, Pa 19141 Ricky : (215) 485-1425

Specializing in Body Kit and Custom Paint

ជំនាញខាងជួសជុលតួរថយន្ត
និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ

RICKY
Hand Ph.: Ricky 215-485-1425

មានបទពិសោធន៍២០ ឆ្នាំ
ជាជាងរថយន្តមានសញ្ញាប័ត្រ
វាយតម្លៃការងារដោយឥតយកថ្លៃ
ហើយយើងជួយសន្សំប្រាក់តម្លៃ
បន្ថយរបស់អ៊ិនស្វូរិន បានផង
យើងផ្តល់សេវាគ្រប់យ៉ាង :

-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C






បើកពីម៉ោង ៩ ព្រឹក
ដល់ម៉ោង៥ល្ងាច ពីថ្ងៃ
ច័ន្ទ ដល់ ថ្ងៃ សៅរ៍
ចុះតម្លៃជូន 10 % បើបង្ហាញប័ណ្ណពាណិជ្ជកម្មនេះ

**New World Travel II**

**ញូវឺលត្រាវែលធូ**

Specialized in Selling Flight Tickets
For National and International

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថេ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations

600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

# “សមាគម អាស៊ាន ជាទារកដែលមានអាយុ ៤៣ឆ្នាំ”

## ដោយសុខធុល ហ្វៃណង់ដេង នាយកក្រុមហ៊ុន “ទេសចរ គេណារី”

*ភ្នំពេញ* : សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលគេតែស្គាល់ក្រោមឈ្មោះថា "អាស៊ាន" (ASEAN) គឺជាអង្គការ នយោបាយ, សេដ្ឋកិច្ច និងវប្បធម៌ ដែលមានប្រជាជាតិចំនួន ១០ នៅអាស៊ីអាគ្នេយ៍ចូលរួម ។ ប្រទេសចំនួន ៥ ដែលបានផ្តួចផ្តើមនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧ នៅទីក្រុងបាងកក ប្រទេសថៃ គឺមានប្រទេស : ឥណ្ឌូនេស៊ី, ម៉ាឡេស៊ី, ហ្វីលីពីន, សឹង្ហបូរី និងប្រទេសថៃ ។ ការផ្តួចផ្តើមនេះ ធ្វើក្នុងក្របខណ្ឌនៃសង្គ្រាមត្រជាក់ដំណើរនៃពួកកុម្មុយនីស្ត ហើយរក្សាលំនឹងក្នុងតំបន់ ។

ក្រោយមកមានប្រទេស ប្រ៊ុយណេ ដារូសាឡឹម ចូលរួមជាបន្ត នៅថ្ងៃទី៨ មករា ឆ្នាំ ១៩៨៤ រួចមក មានវៀតណាម នៅថ្ងៃទី២៨ កក្កដា ឆ្នាំ១៩៩៥ ។ ប្រទេសឡាវ និង ភូមា ចូលរួមនៃថ្ងៃទី២៣ កក្កដា ឆ្នាំ ១៩៩៧ ហើយចុងក្រោយមានយន្តការណ៍សហប្រតិបត្តិការណ៍ក្នុងតំបន់យ៉ាងនេះថា :

១- ជម្រុញល្បឿនសេដ្ឋកិច្ច, ជម្រុញភាពជឿនលឿនសង្គម និងអភិវឌ្ឍន៍វប្បធម៌នៅក្នុងតំបន់ ដោយការប្រឹងប្រែងរួមគ្នានឹងនាំដោយគំនិតស្មើភាពគ្នា ដើម្បីពង្រឹងមូលដ្ឋាននៃសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលសម្បូរសប្បាយ និងសន្តិភាព ។

២- លើកតម្កើងសន្តិភាព និងតុល្យភាពក្នុងតំបន់ ដោយការគោរពនៃយុត្តិធម៌ ហើយនឹងបែបបទនៃច្បាប់នៅក្នុងទំនាក់ទំនងរវាងប្រទេសក្នុងតំបន់ និងដោយចូលជាសមាជិកគោរពគោលការណ៍ច្បាប់នៃអង្គការសហប្រជាជាតិ ។

៣- លើកតម្កើងការចូលរួមសហការណ៍សកម្ម និងជួយគ្នាទៅវិញទៅមកនៅលើប្រធានបទដែលជាប្រយោជន៍រួមនៅក្នុងផ្នែកសេដ្ឋកិច្ច, សង្គមកិច្ច, វប្បធម៌, បច្ចេកទេស, វិទ្យាសាស្ត្រ និងរដ្ឋបាល... ។

នៅក្នុងគំនិតនៃសហប្រតិបត្តិការណ៍រួមសកម្ម ហើយនឹងជួយគ្នាទៅវិញទៅមកនៅលើប្រធានបទប្រយោជន៍រួម សហគមអាស៊ាន បានធ្វើគម្រោងសាងសង់តំបន់ផ្ទេរទំនិញសេរី ។

សមាគមជួបប្រជុំគ្នា ដើម្បីពិភាក្សាពីរឿងផ្សេងៗ ក៏ប៉ុន្តែនៅពេលដែលប្រទេសជាសមាជិករបស់ខ្លួន បានប្រព្រឹត្តអំពើល្មើសណាមួយ ឬក៏ធ្លាក់ ក្នុងវិបត្តិអ្វីមួយ សមាគមនោះ គ្មានសមត្ថភាពនឹងប្រកាន់ជំហរច្បាស់លាស់ទេ ។

. ករណីលោកស្រី អន សាំងស៊ូគី ជ័យលាភីសន្តិភាពណូបែល គេនៅតែឃើញជាប់ឃុំឃាំងនៅភូមានៅឡើយ ។


សុខធុល ហ្វៃណង់ដេង

. ជម្លោះព្រំប្រទល់ដែនខ្មែរ និងថៃ ដែលនៅត្រាំត្រែងមកទល់ថ្ងៃនេះ នៅមិនទាន់ឃើញសមាគមអាស៊ានចាប់អារម្មណ៍នៅឡើយទេ ។

. ឥឡូវនេះ វិបត្តិសង្គមដែលប្រទេសថៃកំពុងឆ្លងកាត់ ក៏មិនទាន់ឃើញមានការផ្សព្វផ្សាយនៅប្រទេសឯទៀតជាសមាជិកនៅឡើយដែរ ! គ្មានវិទ្យុណានិយាយ ! ។

ការកសាងសមាគម អាស៊ាន ត្រូវឆ្លងកាត់ផងដែរ នូវវិចារណញ្ញាណរបស់សហគមន៍ក្នុងការដោះស្រាយបញ្ហាធ្ងន់ធ្ងរដែលផុសឡើងក្នុងគ្រួសារផ្ទាល់របស់ខ្លួនដែរ ។ អាស៊ាន នៅតែជាទារកអាយុ ៤៣ឆ្នាំ ដែលមិនបានខិតខំប្រឹងដើរនៅឡើយ ។

**ភ្នំពេញថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១០**

## សួស្តីឆ្នាំថ្មី សិរីមង្គល !

**ដោយ : អ៊ុក សៅបុល ជ័យលាភីអក្សរសិល្បិ៍ខ្មែរឆ្នាំ១៩៩៧**

| | | |
|---|---|---|
| សួស្តីឆ្នាំថ្មី | ខេមរាប្រុសស្រី | សូមមានចេស្តា |
| សិរីសុខសាន្ត | សន្តានគ្រួសារ | សូមពួកទេព្តា |
| | រក្សាឱ្យជ័យ ។ | |
| ពរ៤ប្រការ | ប្រសើរថ្លៃថ្លា | សូមផុតគ្រោះភ័យ |
| ពុទ្ធពរឧត្តម | ស័ក្តិសមប្រពៃ | ជីវិតមានន័យ |
| | សព្វសត្វមនុស្សា ។ | |
| រៀនសូត្រសីល៥ | ឋិតថេរប្រចាំ | ជាប់ក្នុងអាត្មា |
| ពោលពាក្យសមសត្យ | ទប់ស្កាត់មុសា | ត្រូវមានមេត្តា |
| | ខន្តីក្នុងប្រាណ ។ | |
| ឆ្នាំថ្មីចិត្តថ្មី | លះអន្សតិរិយ | ឫស្យាសាមាន្យ |
| ហិង្សាក្រោធា | វៀរចាកឱ្យបាន | សាងសុខសព្វប្រាណ |
| | កុំបំពានច្បាប់ ។ | |
| កុំសេពគ្រឿងញៀន | ហិនហោចធនធាន | វិញ្ញាណយឺនយ៉ាប់ |
| ខូចខាតស្មារតី | អប្រិយអួរអាប់ | ឆ្នាំថ្មីប្រញាប់ |
| | លះលាអបាយ ។ | |
| ស្តាប់ពាក្យម៉ែឪ | ស្រីស្រាអាស្រូវ | ទៅអន្តរាយ |
| តេចចៀសកុំជិត | ផ្តែកផ្តិចសាហាយ | អសោចកេរ្តិ៍កាយ |
| | អេដស៍ ស្វាយចូលផ្ទះ ។ | |
| សំរាំងចិត្តថ្មី | ឆ្នាំខាលសិរី | ប្រុសស្រីនឹងឈ្នះ |
| ទប់ស្កាត់រោគា | រួមគ្នាជម្រះ | លុបលាងឱ្យជ្រះ |
| | អពមង្គល ។ | |
| ថ្ងូមថៃម៉ែឪ | យាតាសក់ស្កូវ | ជរាទុព្វល |
| អប់រំកូនចៅ | រួសរាយរាក់ទាក់ សំអាតមណ្ឌល | |
| | ថៃគេហដ្ឋាន ។ | |
| ទេព្តាឆ្នាំថ្មី | ផ្តល់សុខសួស្តី | ដល់ញាតិសន្តាន |
| ទៅគ្រប់ទិសទី | រកស៊ីមានបាន | រាស៊ីថ្កើងថ្កាន |
| | បានយសខ្ពស់មុខ ។ | |
| សូមជនប្រុសស្រី | អបអរឆ្នាំថ្មី | បានរំសាយទុក្ខ |
| ឧបទ្រពចង្រៃ | ភយារានរុក | សូមជួបក្តីសុខ |
| | ជានិច្ចនិរន្តរ៍ ៕ | Linn, Mass |

From :Philadelphia



# សួស្តីឆ្នាំថ្មី
## ហាងខ្មែរជួសជុលរថយន្ត
បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

# Rathe`s Auto Service




State and Emission
Inspection General
Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY

-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរប្រ៊្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដូរប្រេងកឺរត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

Yes you can!

... get free or low-cost health insurance for your children.

•Did you lose your health insurance when you lost your job?
•Do your children have no health insurance?
•Do you wonder how you'll afford your kids' next doctor visit?

AmeriChoice
A UnitedHealth Group Company

(215) 360-9841
Leap Thach

Your children deserve to be healthy.
AmeriChoice can help.



# អស់មេ អស់បក្ស



**ដោយ : រស់ យឹន**

•••ក្នុងលេខមុនខ្ញុំបាន សរសេរដ៏សង្ខេប **អំពីជំនឿមិនឡើងថ្នាក់** ដែលផ្តោតសំខាន់ទៅលើព្រះសង្ឃក្នុងសំណាក់ព្រះពុទ្ធសាសនាមួយចំនួនមិនប្រព្រឹត្តធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធ ។ មិនតែប៉ុណ្ណោះ បានច្រឡំបល់ធម៌វិន័យឱ្យទៅជាអមញ្ញាតញ្ញធម៌ ថ្វាយបង្គំព្រះ-សំពះព្រហ្ម-និយមទេវតាប្រាថ្នាបុណ្យសក្តិ កណ្តាច់លាក់ លក់អាត្មាឱ្យទមិឡ ។

ថ្ងៃនេះខ្ញុំចង់បង្ហាញអារម្មណ៍លោកអ្នកអានទៅលើបញ្ហាគណបក្សនយោបាយខ្មែរវិញម្តង ថាតើមានការវិវត្តន៍យ៉ាងណាខ្លះ ?

ជនរួមជាតិទាំងក្នុង និងក្រៅប្រទេសសុទ្ធតែបានជ្រាបអស់ហើយថា របបប្រជាធិបតេយ្យសេរីពហុបក្ស ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រទី២ ជាការបើកចំហរទូលំទូលាយក្នុងការបង្កើតគណបក្សនយោបាយ ។ បានសេចក្តីថា មនុស្សមួយក្រុមបាននាំគ្នាតាក់តែងលក្ខន្តិកៈរួចហើយដើរសុំឈ្មោះ-ផ្តិតមេដៃ-ថតរូប-នារីឡង់សេរ-អ្នកលក់ត្រី-លក់ត្រកួន និងអ្នកសុំទានដោយឱ្យប្រាក់ ២០០០ រៀលទៅ ៣០០០រៀលតែប៉ុណ្ណោះ។ មេបក្សមិនបាច់ពន្យល់ពីសមាជិកភាព និងគោល-ការណ៍នយោបាយអ្វីទេ ព្រោះគេជាកូនអ្នកអន្ទំ ។ រីឯអ្នកទទួលប្រាក់ក៏មិនចង់ដឹងរឿងបក្ស-រឿងពួកអីដែរចង់យកឈ្មោះ-ស្នាមមេដៃ-រូបថតទៅធ្វើប៉ាវ៉ែនតុក្កតាស៊ីក៏ធ្វើទៅ ។ លុះបានគ្រប់ចំនួន ៤៥០០នាក់ គេយកដឹម៉ង់ទៅដាក់ជូនក្រសួងមហាផ្ទៃ ។ រួចហើយនាយកដ្ឋាននយោបាយរបស់ក្រសួងដាក់ជូនរដ្ឋមន្ត្រីចុះហត្ថលេខាជាការស្រេច។ គ្រានោះឯងពួកគេបានប្រសូតគណបក្សមួយដ៏មហិមាបញ្ជូនសំណុំរឿងទៅជូន គ.ជ.ប ភ្លាម ។ ជាមួយនឹងប្រធានបក្សស្នេហាជាតិលិ្ងតឈឹង ឬវ៉ៃឆ្វាត មានចំណេះរបេះក្បាច់ ។ ជួនកាលបានប្រធានបក្សជាកូនអ្នកធំធូរធារ រលោតែ ឥតស្គាល់ទិសតំបន់អ្វីទាំងអស់ ឬប៉ះចំមេកញ្ជិលផេះខ្ទះតម្រិះចេះតែថា អាប់ប្រាជ្ញា ក្លាសំដី ថ្វីតែមាត់ ដេកចាំតែសំណាងក៏មាន ។ ជួនកាលមេបក្សខ្លះជាព្រះស្តែងតាំងថាខ្លួន ជាព្រះបាទធម្មិក ពពីកភ្នែកអែរ ។ គេមិនប្រឹងប្រែងរៀបចំរចនាសម្ព័ន្ធ និងចងក្រងយុទ្ធសាស្ត្រនយោបាយ ប្រឈមទៅនឹងសភាពការណ៍ចំពោះមុខបើកចក្ខុវិស័យមើលអាយុជីវិតជាតិ-មាតុប្រទេសនៅថ្ងៃអនាគតឡើយ ព្រោះគេខ្វះសមត្ថភាពក្នុងការក្តាប់ស្ថានការណ៍នយោបាយ ។ ម្លោះហើយកាលបើដំណើរការឆ្ងាយបន្តិចទៅត្រូវច្បាប់នៃរបបនយោបាយហ៊ុំព័ទ្ធជាប់ស្វេញ ។ ពួកគេក្លាយជាគណបក្សសេះហោះ។ ដើរបោកប្រាស់ខ្មែរក្នុងស្រុកខ្លះក្រៅស្រុកខ្លះ ហើយអែបអប លេមឡើមជាមួយពួក ហ៊ូ ជីមិញ និយមខ្លះបានស៊ីបានដឹកស្រវឹងក្អួតចាក់ទឹងហ៊ុងហោងហៅស្រីយួនកោសខ្យល់... ។

ដោយឡែក ដង្ហោនយោបាយដ៏ធំមួយនៅឧបទ្វីបឥណ្ឌូចិន ឈ្មោះ ង្វៀន អៃកុក (ហូជីមិញ) បានប្រែក្រឡាចងក្រងយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិននៅខេត្តខាវលន់ (ហុងកុង) តាំងពីឆ្នាំ១៩៩៣ មកម្លេះ។ ពួកគេបន្តវេណបណ្តាក់ដៃគ្នាពង្រីងជំហរដើរតាមបន្ទាត់បហិច្ឆិតារបស់គេសំរេចបានជោគជ័យយកទឹកដីលាវ-ខ្មែរជាជ័យភ័ណ្ឌរហូតសព្វថ្ងៃ ។

យើងក្រឡេកមើលពីចំងាយឃើញការវិវត្តន៍នយោបាយខ្មែរ ហាក់បីដូចជាមានទំនើបកម្មយ៉ាងសម្បើមណាស់ ប៉ុន្តែបើយើងចូលឱ្យជ្រៅ ហើយក្បៀកកិតបន្តិច ទើបមើលឃើញថា ភាគច្រើនជាគណបក្សសំបកប៉ោតសោះ។

ដោយឡែក គណបក្សបន្តសន្តិវង្ស ឬបន្តវេណពីឪម៉ែជាអភិជនល្បីឈ្មោះទាំងនោះ សុទ្ធតែជាគណបក្សពេញនិយម ព្រោះប្រជារាស្ត្រចូលចិត្តពូជស្តេច, ពូជកូនមេទ័ព, ពូជកូនអ្នកការទូតដ៏ល្បីៗហើយទុកចិត្តសុំចុះចូលយ៉ាងគគ្រឹកគគ្រេង ។ ប្រជាពលរដ្ឋលោកគិតថា មេបក្សជាកូនស្តេច, មន្ត្រី, សេដ្ឋី, អ្នកមានទាំងនោះ សុទ្ធតែជាបញ្ញាវន្តស្នេហាជាតិដ៏មោះមុតបំផុត គាត់មិនបានពិនិត្យទៅលើគោលការណ៍ ឬរចនាសម្ព័ន្ធរបស់បក្សដែលមានខ្លឹមសារជាយុទ្ធសាស្ត្ររំដោះជាតិពីក្រញ៉ាំបិសាចយួន-ចិននោះទេ (sic) មេបក្សដ៏មហិមារទាំងនោះបះហើយ បោរទៅវិញ លិ្ងតលិ្ងន់ ទន់ខ្សោយដាច់ក្បាលដាច់កន្ទុយ អស់មេ ក៏អស់បក្ស រលំដួលជាបន្តបន្ទាប់ ។ ចាប់ពីឆ្នាំ ១៩៩៣ មកបក្សធំៗរលំអស់ប៉ុន្មានហើយ ?

ដដែលជាដដែល!!! កូនចៅ ហូ ជីមិញ និយមគេខំជួយលើកឡើងវិញម្តងជាពីរដង ដើម្បីបង្ហាញពលរដ្ឋខ្មែរថា មិនមែនពួកគេជាអ្នកធ្វើយុទ្ធវិធីជាន់ក្បាលពន្លិចនោះទេ គឺពួកមេបក្សមិនគ្រប់ទឹកទាំងនោះ ដើរដួលដោយខ្លួនឯង ។ បងប្អូនខ្មែរអ្នកកាន់សាសនាព្រះពុទ្ធ ហើយដែលជាសាធារណៈបុគ្គលរិះគិតមើលចុះ តើយើងត្រូវបន្តដើរតាមមេបក្សចោលម្សៀត ឬយើង និងជាតិយើងត្រូវតែតស៊ូជាមួយមេបក្សណាដែលមានយុទ្ធសាស្ត្ររំដោះជាតិ និងសាសនាពិតប្រាកដ ៕


## ចម្លើយ "ខ្មែរប៉ុស្តិ៍" ដែលមានរង្វាន់

សំនួរ **១- តើទន្លេមេគង្គមានប្រវែងសរុបទាំងអស់ប៉ុន្មានគីឡូម៉ែត្រ?**
**ឆ្លើយ** : ៤.៣៥០ គីឡូម៉ែត្រ
**២- ចាប់ផ្តើមហូតចេញពីណា ? ឆ្លើយ :** ពីខ្ពង់រាបទីបេត៍
**៣-ឆ្លងកាត់ប្រទេសណាខ្លះ ? ឆ្លើយ :** ពីប្រទេសចិន (ខេត្តយុនណាន) ភូមា,ឡាវ, ថៃ, ខ្មែរ និងវៀតណាម ។
- ចម្លើយត្រូវដែលមានរង្វាន់ : គ្មាន - ចំនួនអ្នកបានឆ្លើយ : 0

## ផ្ទះ Duplex សំរាប់ជួល

-នៅតំបន់ Mi Airy, Philadelphia ជាន់ទី១ មាន២បន្ទប់ មាន Central Air មានម៉ាស៊ីនបោក និងហាលខោអាវ-មានធុងចោលសំរាម, ដាក់ព្រំពេញបន្ទប់, មានកន្លែងដាក់ឡាន
-តម្លៃជួល $ 825/១ខែ + ថ្លៃទឹក ភ្លើង
-ទូរស័ព្ទ : **267-243-7039**

## រកស្ត្រីអ្នកធ្វើក្រចក

មានបច្ចេកទេស និង Licence PA. ធ្វើការនៅ Strousburg PA. ចម្ងាយ ២ ម៉ោងពីហ្វីឡា មានបន្ទប់ជូនសំរាក-ព័ត៌មានបន្ថែមទូរស័ព្ទ 570-350-4114
570-424-9466

## Yoo's Auto Service and Collision

## យូ បំរើសេវារថយន្ត
នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច

FREE ESTIMATES

យើងនឹងជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត តាមតែយើងធ្វើបាន ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។




189 W. Duncannon Ave. Phila., PA 19120

COUPON
$10 OFF TOWARD EMISSION AND STATE INSPECTION

**សេវាជាងម៉ាស៊ីន**
Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission
Inspection & Repairs
Muffler & More

**សេវាជួសជុលតួរថយន្ត**
Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists

**ទូរស័ព្ទរក SAM 215-457-7777 ឬ 215-457-7779, Fax-215-457-7475**

# គណបក្ស សម រង្ស៊ី

## សីលធម៌-សច្ចធម៌-យុត្តិធម៌



# សេចក្តីអញ្ជើញ

## ស្វែងយល់ការពិត ដើម្បីការពារបូរណភាពទឹកដីកម្ពុជា

យោងទៅតាមព្រឹត្តិការណ៍ក្តៅគគុកនៅឯប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ ដូចជា ការទាក់ទិននឹងបញ្ហាសិទ្ធិមនុស្ស បញ្ហាព្រំដែន បញ្ហានយោបាយដែលទាក់ទាមទៅនឹងប្រទេសជិតខាងជាដើមនោះ យើងខ្ញុំសូមគោរពអញ្ជើញបងប្អូនជនរួមជាតិទាំងអស់ មេត្តាចូលរួមជំនុំពិភាក្សា និងជួបជាមួយលោក **សម រង្ស៊ី** ជាប្រធានគណកប្ស សម រង្ស៊ី សមាជិការដ្ឋសភា និងតំណាងរាស្ត្រ ដើម្បីសួរផ្ទាល់ក្នុងបុព្វហេតុនិងមាតុភូមិខ្មែរ។

# PUBLIC INVITATION

## SEEKING THE TRUTH TO DEFEND CAMBODIA TERRITORIAL INTEGRITY

Based on the heated situation in Cambodia today, such as problems related to human rights, border and political situation that involved neighboring countries, we would like to invite our entire compatriot to attend a conference meeting with Mr. Sam Rainsy, SRP President and elected Member of Parliament from Cambodia.

**For more information please contact SRP/PA:**
Email: samrainsyparty.usa@gmail.com

| | |
|---|---|
| Mr. Meas Chea | (215) 833-3669 |
| Mr. Leang Bunlee | (215) 880-6419 |
| Mr. Ros Alex | (267) 570-7449 |
| Mr. R. Visal | (215) 439-1553 |

**Date:** Sunday - May 23, 2010
**Time:** 6:00 PM - 9:00 PM
**Location:** Grand King Restaurant
40-44 Snyder Ave. Philadelphia, PA 19148
SNYDER PLAZA (Snyder Ave. & Water St.)
**Admission:** $15/Person - Dinner Included!




samrainsyparty.usa@gmail.com http://www.samrainsyparty.org

SAM RAINSY PARTY OF PENNSYLVANIA, USA

INTEGRITY - HONESTY - JUSTICE